ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- បណ្ណាល័យសម្តេចម៉ែ ប្រារព្ធខួបទី៨ នៃការយាងសោយទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋនៅវត្តលង្កា
- ភ្ញៀវទូតទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥០ ខែតុលា ឆ្នាំ២០២០

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥០ ខែតុលា ឆ្នាំ២០២០

# មាតិកា

## សំបុត្រ

◆ បណ្ណាល័យសម្តេចម៉ែ ប្រារព្ធខួបទី៨នៃការយាង សោយទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋ..... ១
◆ ភ្ញៀវទូតទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ ..... ៤
◆ ការថែរក្សាសន្តិភាពនិងការអភិវឌ្ឍ នៅស្រុកអន្លង់វែង ......................... ៤០

## ផ្នែកឯកសារ

◆ ណាំ សា ៖ អតីតសាស្ត្រាចារ្យមហាវិទ្យាល័យ គរុកោសល្យ ផ្នែកគីមីវិទ្យា និង រូបវិទ្យា... ៤៤

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ គ្រាន់តែហូបផ្លែត្របែក ធ្វើឲ្យជីវិតខ្ញុំស្ទើរស្លាប់ ....................... ៤៨

## ផ្នែកច្បាប់

◆ សាលក្រមសំណុំរឿង០០២/០២ ............ ៥៣

## ផ្នែកវេទិកាសាធារណៈ

ក្រុមយុវជនសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម................ ៥៦

## ផ្នែកស្រាវជ្រាវរកគ្រួសារ

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
◆ ជ័យ ផុន ៖ គ្រូបង្រៀន ....................... ៦០



អ្នកអង្គម្ចាស់ក្សត្រី នរោត្តម រស្មីពនិតា ចូលរួមប្រារព្ធខួបទី៨នៃការយាងសោយទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ នៅវត្តលង្កា រាជធានីភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ឆាំង យុ, ប៊ាង ពីរីន្ត, វេនី ខកហ្កៀល,
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ផុនា,ដារ៉ាវរដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** ហួយ លីយាង
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ផុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉ែង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# បណ្ណាល័យសម្តេចម៉ែ ប្រារព្ធខួបទី៨ នៃការយាងសោយទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋ

**ឆាំង យុ**



"បណ្ណាល័យសម្តេចម៉ែ" នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រារព្ធខួបទី៨នៃការយាងសោយទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២ នៅវត្តលង្ការាជធានីភ្នំពេញ។

គួរបញ្ជាក់ថា នេះគឺជាលើកទីមួយដែលវត្តលង្កាប្រារព្ធពិធីខុទ្ទិសកុសលនេះឡើង។ កាលពីឆ្នាំ២០១២ បន្ទាប់ពីព្រះរាជពិធីថ្វាយព្រះភ្លើង វត្តលង្កាក៏ទទួលបានបំណែកនៃព្រះរាជឫកធាតុរបស់ព្រះបរមរតនកោដ្ឋដើម្បីតម្កល់ទុកនៅក្នុងបុស្សបុក និងរៀបចំពិធីជារៀងរាល់ឆ្នាំ។



ពិធីនេះ ទទួលបានការចូលរួមពីសំណាក់ព្រះរាជវង្សានុវង្ស២៥រូប ក្នុងឱកាសដែលសម្តេចម៉ែ និងព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់យាងពិនិត្យព្រះរាជសុខភាពនៅឯទីក្រុងប៉េកាំង, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកឯកអគ្គរាជទូតបណ្ឌិត ហ្ជូលីយ៉ូ អេ. ជែលជ្រេស អតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ។

សម្តេចព្រះធម្មលិខិតបណ្ឌិត សៅរ៍ ចន្ទថុល ព្រះចៅអធិការវត្តលង្កា បានយាងសូត្រមន្តចម្រើនព្រះបរិត្ត និងឧទ្ទិសកុសលផលបុណ្យជូនដល់ព្រះវិញ្ញាណក្ខន្ធសម្តេចព្រះបរមរតនកោដ្ឋ។ សម្តេចព្រះធម្មលិខិតបណ្ឌិត នឹងតម្កល់ព្រះរាជបុកធាតុនិងរៀបចំពិធីរំឭកនេះរយៈពេលបីថ្ងៃ ដើម្បីអនុញ្ញាតដល់រាជវង្សានុវង្សដែលមិនអាចចូលរួមក្នុងថ្ងៃនេះ បានចូលរួម។

បន្ទាប់ពីពិធីបង្សុកូលឧទ្ទិសកុសលបានចប់សព្វគ្រប់ រាជវង្សានុវង្សដែលមានវត្តមាននៅក្នុងពិធីនេះ បានចុះទៅសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាជនរងគ្រោះដោយទឹកជំនន់ក្នុងខេត្តកំពង់ស្ពឺ។ កាយវិការនេះ គឺជាការផ្តាំផ្ញើតំណាងឲ្យព្រះរាជហឫទ័យព្រួយបារម្ភ និងយកព្រះទ័យទុកដាក់ដល់សុខទុក្ខប្រជាជនរួមជាតិរបស់សម្តេចម៉ែនិងព្រះមហាក្សត្រកម្ពុជា ថ្វីបើទ្រង់មិនបានគង់នៅក្នុងប្រទេសយ៉ាងណាក្តី។













សម្តេចព្រះធម្មលិខិតបណ្ឌិត សោវ៍ ចន្ទផុល្ល, ព្រះរាជវង្សានុវង្ស, ឯកអគ្គរាជទូតបណ្ឌិត ហ្គូលីយ៉ូ អេ. ដែលជ្រេស និងលោកឆាំង យុ បាននិមន្ត, យាង និងចូលរួមប្រារព្ធខួបទី៨នៃការយាងសោយទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ នៅវត្តលង្កា។ (សន ប៊ុនស៊ឹម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ភ្ញៀវទូតទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ

ឆាំង យុ

បន្ទាប់ពីពិធីសម្ពោធជាផ្លូវការនូវបណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល កាលពីវេលាព្រឹកថ្ងៃទី២១ខែកញ្ញា ឆ្នាំ២០២០ កន្លងមក មានភ្ញៀវទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជាមកទស្សនកិច្ចបណ្ណាល័យ សម្តេចម៉ែជាបន្តបន្ទាប់៖

## ព្រះរាជាណាចក្រថៃ







នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ លោក ប៉ាន់យ៉ាវ៉ាក់ ពុលថាប់ ឯកអគ្គរាជទូតថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា រួមទាំងប្រតិភូទូតថៃ២២រូបទៀត បានអញ្ជើញមកទស្សនាបណ្ណាល័យសម្តេចម៉ែដោយផ្ទាល់។ ទស្សនកិច្ចនេះត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ ស្ថាបនិកវិទ្យាស្ថានស្លឹក និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់ពីទស្សនកិច្ច ឯកអគ្គរាជទូតលោក ប៉ាន់យ៉ាវ៉ាក់ ពុលថាប់ បានសរសេរលើសៀវភៅក្រាំងមាសបណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។





# ជំទាវទូត





នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ សម្តេចព្រះរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី ព្រះអង្គបានយាងអញ្ជើញ និងអមដំណើរភរិយាឯកអគ្គរាជទូត-រដ្ឋទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា រួមមាន ទូតម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី ឡាវ អាមេរិក និងកូរ៉េខាងត្បូងមកទស្សនាបណ្ណាល័យសម្តេចម៉ែ។ ទស្សនកិច្ចនេះត្រូវបានទទួលការស្វាគមន៍ពីលោក ឆាំង យុ ស្ថាបនិកវិទ្យាស្ថានស្លឹក និងជានាយកមជ្ឈមណ្ឌលឯកសារ និងឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ជែលជ្រេស អតីតលេខាផ្ទាល់និងជាអ្នកនិពន្ធជីវប្រវត្តិរបស់ព្រះករុណាព្រះមហាវីរក្សត្រព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ។ បន្ទាប់ពីទស្សនកិច្ច លោកជំទាវទូត បានសរសេរលើក្រាំងមាសបណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។











# រុស្ស៊ី











នាវេលាម៉ោង៩ព្រឹក ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក អាណាតូលី បូរ៉ូវីគ អមដំណើរដោយភរិយារបស់លោក និងមន្ត្រីស្ថានទូត ចំនួន១០រូបផ្សេងទៀត បានអញ្ជើញទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ទស្សនកិច្ចរបស់ប្រតិភូស្ថានទូតរុស្ស៊ីនាព្រឹកនេះ បង្ហាញអំពីឆន្ទៈរបស់លោកឯកអគ្គរដ្ឋទូតរុស្ស៊ី ក្នុងការឈ្វេងយល់អំពីវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា បន្ទាប់ពីលោកទទួលតំណែង និងធ្វើដំណើរមកកាន់ព្រះរាជាណាចក្រកម្ពុជាអស់រយៈកាលជាង២ខែកន្លងមក គិតចាប់ពីខែកក្កដា ឆ្នាំ២០២០ថ្មីៗនេះ។ ទស្សនកិច្ចរបស់ប្រតិភូក្នុងអំឡុងរយៈពេលជាង២ម៉ោងនេះ ប្រព្រឹត្តទៅយ៉ាងរលូន និងប្រកបដោយខ្លឹមសារជ្រាលជ្រៅ។

លោក ឆាំង យុ នាយកវិទ្យាស្ថានស្លឹករឹត និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្តែងនូវអំណរគុណជាអនេកចំពោះការចំណាយពេលដ៏មានតម្លៃរបស់ប្រតិភូរុស្ស៊ី មកកាន់បណ្ណាល័យសម្តេចម៉ែ។ លោក ឆាំង យុ បានបញ្ជាក់អំពីការគាំទ្ររបស់លោកចំពោះប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលស្នើឲ្យប្រទេសរុស្ស៊ីផ្តល់ជំនួយជាវ៉ាក់សាំងព្យាបាលជំងឺរាតត្បាតកូវីដ១៩ ដែលជាក្តីកង្វល់របស់មនុស្សជាតិនាពេលបច្ចុប្បន្ន។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ច ឯកឧត្តមឯកអគ្គរដ្ឋទូត បានសរសេរសំណេរអនុស្សាវរីយ៍នៅលើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានខ្លឹមសារដូចខាងក្រោម ៖

---

**«នេះពិតជាកិត្តិយសដ៏វិសេសវិសាល ដោយខ្ញុំបានធ្វើទស្សនកិច្ចមកកាន់ បណ្ណាល័យសម្តេចម៉ែ ដែលជាកិច្ចផ្តួចផ្តើមរបស់លោក ឆាំង យុ និងក្រុមការងារវិទ្យាស្ថានស្លឹករឹត ព្រមទាំងបានជ្រាបអំពីការចងចាំល្អៗផ្ទាល់ព្រះកាយរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងរាជវង្សានុវង្ស។ សម្តេចព្រះបរមរតនកោដ្ឋនឹងស្ថិតនៅក្នុងការចងចាំរបស់យើង គឺជាមិត្តល្អមួយអង្គរបស់រុស្ស៊ី និងជាអ្នកថែរក្សាសន្តិភាព និងស្ថិរភាពដ៏អង់អាចមួយព្រះអង្គរបស់កម្ពុជា»។**

---

# អង់គ្លេស

លោក ម៉ាក្ស ថេរី ភារធារី តំណាងឲ្យស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា បានធ្វើទស្សនកិច្ចមកកាន់បណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

នៅក្នុងអំឡុងទស្សនកិច្ចប្រមាណជាងពីរម៉ោង លោក ថេរី ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រុមការងារ។ ជាកិច្ចចាប់ផ្តើម លោកឯកអគ្គរាជទូត ហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ បាននិយាយរៀបរាប់ពិព័រណ៌ស្តីអំពីព្រះឆាយាលក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងរាជវង្សានុវង្ស ដែលតាំងបង្ហាញនៅបណ្ណាល័យសម្តេចម៉ែ។ លោក ឆាំង យុ បានបង្ហាញភ្ញៀវកិត្តិយសនូវបន្ទប់បណ្ណាល័យរូបថតឯកសារ បណ្ណាល័យសោតទស្សន៍ និងបណ្ណសារឌីជីថលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងបានពិពណ៌នាយ៉ាងពិស្តារអំពីប្លង់រចនានិងសារៈតាររបស់វិទ្យាស្ថានស្ថានស្លឹករឹត ដែលជាស្នាដៃរបស់ស្ថាបត្យករកម្រិតពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ ដែលមានសញ្ជាតិអង់គ្លេសដើមកំណើតអ៊ីរ៉ាក់។

គួរបញ្ជាក់ថា នៅក្នុងឆ្នាំ២០១៨ លោកស្រី ហ្សាហា ហាឌីដ នាយកស្ថាបត្យកម្ម ហ្សាហា ហាឌីដ និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើសេចក្តីប្រកាសរួមអំពីកិច្ចសហប្រតិបត្តិការជាមួយស្ថាបត្យកម្មរបស់លោកស្រី ហាឌីដ ក្នុងការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត ដែលគឺជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីរំឭក និងឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតប្រមាណ២លាននាក់ នាអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

ស្នាដៃស្ថាបត្យកម្មនានារបស់លោកស្រី ហ្សាហា ហាឌីដ ត្រូវបានពិភពលោកទទួលស្គាល់ និងកោតស្ញប់ស្ញែងយ៉ាងក្រៃលែង។ នៅឆ្នាំ២០១០ និងឆ្នាំ២០១១ ស្នាដៃស្ថាបត្យកម្មរបស់លោកស្រី ទទួលបានពានរង្វាន់ស្ទឺលីង ពីវិទ្យាស្ថានស្ថាបត្យករអង់គ្លេស។ អគ្គការ







យូណេស្កូបានតាំងគោរមងារជូនលោកស្រី ហុងរ៉ាហា ហាឌីដ ជា «សិល្បករដើម្បីសន្តិភាព»។ សាធារណរដ្ឋបារាំងបានផ្តល់កិត្តិយសដល់ លោកស្រី ហុងរ៉ាហា ហាឌីត ជាមួយនឹង មេដាយសិល្បៈនិងអក្សរសាស្ត្រ។ នៅឆ្នាំ២០១២ ម្ចាស់ក្សត្រិយានី អេលីហ្សាបែតទីពីរ បានប្រទានគ្រឿងឥស្សរិយយសថ្នាក់ធិបឌិន្ទ ដល់លោកស្រី ហុងរ៉ាហា ហាឌីដ។ នៅឆ្នាំ២០១៦ មុនពេលទទួលអនិច្ចកម្ម លោកស្រី ហុងរ៉ាហា ហាឌីដ គឺជាស្ថាបត្យករស្រ្តីតែមួយរូបគត់ និងដំបូងបំផុតក្នុងរយៈកាលជាង ១៦០ឆ្នាំកន្លងមក ដែលទទួលបានមេដាយរាជមាសពីស្ថាប័នស្ថាបត្យកម្មរបស់រាជវង្សអង់គ្លេស។

លោក ម៉ាក្ស ថេរី បានបង្ហាញចំណាប់អារម្មណ៍យ៉ាងជ្រាលជ្រៅចំពោះបណ្ណាល័យសម្តេចម៉ែ ព្រមទាំងការងាររចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងការងារដែលទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ជាពិសេសលើប្លង់រចនារបស់វិទ្យាស្ថានស្លឹករឹត ដែលជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានចោទជាសំណួរសំខាន់ៗជាច្រើនអំពីដំណើរការចងក្រងឯកសារប្រវត្តិសាស្ត្រ។ នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ច លោក ម៉ាក្ស ថេរី បានចារនូវសំណេរអនុស្សាវរីយ៍នៅលើសៀវភៅក្រាំងមាសរបស់បណ្ណាល័យសម្តេចម៉ែ មានខ្លឹមសារដូចខាងក្រោម៖

***"គំណាងឱ្យស្ថានទូតអង់គ្លេសប្រចាំនៅរាជធានីភ្នំពេញ ក៏ដូចជារដ្ឋាភិបាលចក្រភពអង់គ្លេស ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោកក្នុងការតាំងបង្ហាញនូវពិព័រណ៍ដ៏មានសារសំខាន់នេះ។ យើងអាចមានការយល់ដឹងបានច្បាស់លាស់បំផុត នៅពេលដែលយើងសិក្សាអំពីប្រវត្តិសាស្ត្រ។ ខ្ញុំសូមអបអរសាទរចំពោះលោក និងក្រុមការងាររបស់លោក"*** ។





# ទីម័រខាងកើត









កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី១ ខែតុលា ឆ្នាំ២០២០ ឯកឧត្តម អ៊ែម៉ែនីហ្សិលឌូ គូបប៉ា ឡូប៉េស ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត អមដំណើរដោយមន្ត្រី និងបុគ្គលិករបស់ស្ថានទូត បានធ្វើទស្សនកិច្ចមកកាន់បណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកឯកអគ្គរាជទូត ហូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ រួមទាំងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្តែងការរាក់ទាក់ស្វាគមន៍ប្រតិភូតំណាងស្ថានទូតទីម័រខាងកើតយ៉ាងកក់ក្តៅ។

ក្នុងអំឡុងទស្សនកិច្ចនេះ ប្រតិភូតំណាងស្ថានទូតទីម័រខាងកើត បានទស្សនានិងទទួលជ្រាបអំពីព័ត៌មានទាក់ទងនឹងពិព័រណ៍ដ៏កម្រនៃព្រះឆាយាល័ក្ខណ៍នៃសម្តេចព្រះបរមរតនកោដ្ឋ សម្តេចព្រះវររាជមាតាជាតិខ្មែរ និងព្រះរាជវង្សានុវង្ស ទាក់ទងនឹងព្រះរាជសកម្មភាពកាលពីអតីតកាលរបស់ទ្រង់។ ទន្ទឹមនឹងនេះ លោកឯកអគ្គរដ្ឋទូត ក៏បានទស្សនាបរិក្ខានានានៅក្នុងបណ្ណាល័យ រួមមាន សមុច្ច័យជាសៀវភៅឯកសារ និងឯកសារសោតទស្សន៍យ៉ាងច្រើនសម្បើម ដែលមជ្ឈ-មណ្ឌលឯកសារកម្ពុជាបានស្រាវស្រង់ខិតខំប្រមែប្រមូលចងក្រងអស់ប្រមាណជាង២០ឆ្នាំកន្លងមក។ លោក ឆាំង យុ ថែមទាំងបានបង្ហាញរៀបរាប់អំពីប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹត ដែលជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្នាដៃរបស់ស្ថាបត្យករកម្រិតពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ។ បន្ទាប់មក លោកស្រី ស៊ូ ហ្សារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបរាប់និងបង្ហាញនូវទីតាំងមជ្ឈមណ្ឌលស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំង៦ទីតាំងនៅតាមបណ្តាខេត្ត ជូនប្រតិភូស្ថានទូតទីម័រខាងកើតដែរ។

នៅចុងបញ្ចប់នៅទស្សនកិច្ច លោកឯកអគ្គរដ្ឋទូត បានធ្វើការពិភាក្សាជាមួយនឹងលោក ឆាំង យុ និង ក្រុមការងារលើប្រធានបទមួយចំនួនស្តីពី ដំណើរការចងក្រងឯកសារ ប្រវត្តិសាស្ត្រស្រដៀងគ្នារវាង ប្រទេសទាំងពីរ និងដំណើរការផ្សះផ្សារជាតិដែលប្រព្រឹត្តទៅនៅក្នុងប្រទេសទាំងពីរ។ ក្នុងឱកាសនោះ លោក ឆាំង យុ បានបង្ហាញឯកសាររូបថតមួយចំនួនទាក់ទងនឹងប្រទេសទីម័រខាងកើតដែលបានរក្សាទុកនៅបណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជូនលោក អ៊ែម៉ែនីហ្សិលឌូ គូបប៉ា ឡូប៉េស។

នៅមុនពេលទស្សនកិច្ចបញ្ចប់ ក្រុមប្រតិភូ និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានថតរូបអនុស្សាវរីយ៍ជាក្រុម។ លោកឯកអគ្គរដ្ឋទូតគូបប៉ា បានចារសំណេរអនុស្សាវរីយ៍នៅលើសៀវភៅក្រាំងមាសរបស់បណ្ណាល័យសម្តេចម៉ែ មានអត្ថន័យដូចតទៅ៖

**«តំណាងឱ្យប្រជាជន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ក្នុងនាមជាឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជា ខ្ញុំពិតជាមានសេចក្តីកោតសរសើរយ៉ាងអនេកចំពោះបណ្ណាល័យសម្តេចម៉ែ។ សង្ឃឹមថាការទស្សនកិច្ចក្នុងសមាសភាពជាអគ្គរដ្ឋទូតរបស់ខ្ញុំនេះ អាចជំរុញឱ្យមានសហប្រតិបត្តិការរវាងទីម័រខាងកើត និងកម្ពុជា តាមរយៈបណ្ណាល័យសម្តេចម៉ែនេះ ។**

**ដោយសេចក្តីគោរពដ៏ស្មោះស្ម័គ្រ**
**អ៊ែម៉ែនីហ្ស៊ីលឌូ គូបប៉ា ឡូប៉េស**
**អគ្គរដ្ឋទូត »**





# ប្រតិភូតំណាងឱ្យក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា



ប្រតិភូស្ត្រីចំនួន ១៧រូប តំណាងឲ្យក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នារសៀលថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០។ ទស្សនកិច្ចនេះគឺជាកិច្ចផ្តួចផ្តើមរបស់សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងាររបស់លោក បានទទួលស្វាគមន៍ប្រតិភូកិត្តិយសយ៉ាងកក់ក្តៅ។ ដំណើរទស្សនកិច្ច ចាប់ផ្តើមដោយការរៀបរាប់យ៉ាងពិស្តារអំពីព័ត៌មាននៃព្រះឆាយាលក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ, សម្តេចព្រះវររាជមាតាជាតិខ្មែរ និងរាជវង្សានុវង្ស ផ្តល់ដោយលោកឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរព្រះជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ អមជាមួយនឹងភ្លេងដែលជាព្រះរាជនិពន្ធរបស់សម្តេចព្រះបរមរតនកោដ្ឋ។

លោក ឆាំង យុ បានបង្ហាញដល់ប្រតិភូនូវបណ្ណាល័យដែលផ្ទុកឯកសារជាសៀវភៅរាប់ពាន់ក្បាល និងឯកសាររាប់សែនសន្លឹក, ឯកសារសំណៅដើម, បណ្ណសារជារូបថតនិងវីដេអូ, បណ្ណសារសោតទស្សន៍ និងបរិក្ខារផ្ទុកឯកសារជាទម្រង់ឌីជីថលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់។ លោក ឆាំង យុ ថែមទាំងបានរៀបរាប់យ៉ាងលម្អិតអំពីសាវតារ និងអត្ថន័យនៃប្លង់រចនារបស់អគារវិទ្យាស្ថានស្លឹករឹត។

លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញអំពីទីតាំង “បណ្ណាល័យនិងមជ្ឈមណ្ឌលស្រាវជ្រាវឯកសារខ្មែរក្រហម” ទាំង៦នៅតាមបណ្តាខេត្ត រួមជាមួយនឹងសៀវភៅអំពីស្ត្រីជនជាតិចាមមូស្លីមដែលជាស្នាដៃនិពន្ធរបស់លោកស្រី។ នៅចុងបញ្ចប់នៃទស្សនកិច្ច ប្រតិភូកិត្តិយស និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានរួមពិភាក្សាអំពីបញ្ហានានាជុំវិញការអភិរក្សនិងចងក្រងឯកសារ សោកនាដកម្មនានា ដែលស្ត្រីប្រឈមនៅក្នុងរបបខ្មែរក្រហមនិង

ផលវិបាកនៃរបបនេះ ព្រមទាំងតួនាទីរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍ។

ក្រោយពីការដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានបន្សល់នូវអ្នករស់រានមានជីវិតភាគច្រើនជាស្ត្រីនិងកុមារ ដែលមានចំនួនរហូតដល់ទៅ៦៥% នៃប្រជាជនសរុបនាពេលនោះដែលមានប្រមាណ៥លាននាក់។ ស្ត្រីបានក្លាយជាកម្លាំងស្នូលក្នុងការស្តារនិងកសាងប្រទេសជាតិឡើងវិញបន្ទាប់ពីវត្តមាននៃអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាលនិងជម្លោះរ៉ាំរ៉ៃជាច្រើនទសវត្សរ៍។ ដោយមានការជំរុញនិងយកចិត្តទុកដាក់ក្នុងការបង្កើននិងពង្រឹងសមភាពយេនឌ័រពីសំណាក់រាជរដ្ឋាភិបាល ស្ត្រីកម្ពុជា ជាច្រើនបានវិវត្តចេញពីតួនាទីបែបប្រពៃណីដែលកំណត់ថាស្ត្រីគួរតែនៅមើលថែផ្ទះសម្បែង ជាជាងចូលរួមនៅក្នុងមុខតំណែងសំខាន់ៗក្នុងជួររដ្ឋាភិបាល ជំនួញ ការអប់រំ និងវិស័យដទៃទៀតជាច្រើន។

លោកជំទាវ ស្រួ ណារីយ៉ា បានចែករំលែកចំណាប់អារម្មណ៍ថា៖ “ទីមួយ ខ្ញុំយល់ថាការរៀបចំរបស់គាត់វាល្អខ្លាំង ព្រោះអគារនេះ គឺជាអគារបុរាណ ប៉ុន្តែការតាំងរបស់គាត់គឺមានគំនិតច្នៃប្រឌិតខ្ពស់ ជាពិសេសកន្លែងតាំងពិព័រណ៍រូបថត ដែលមានលក្ខណៈសហសម័យ (រួមបញ្ចូលទាំងបុរាណនិងទំនើប)។ មួយទៀតទាក់ទងជាមួយនឹងការរៀបឯកសាររបស់គាត់ ថ្វីត្បិតតែកន្លែងមិនសូវទូលាយ ប៉ុន្តែការរៀបចំប្រកបទៅដោយសិល្បៈ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេគឺ លោកឆាំង យុ បានលើកឡើងថា ការរៀបចំទាំងអស់គឺកើតចេញពីបេះដូង។ ហើយខ្ញុំសង្ឃឹមថាអគារស្ទើករីតនឹងលេចចេញជារូបរាងនៅពេលឆាប់ៗ ហើយនឹងកាន់តែល្អខ្លាំងនៅពេលដែលខ្មែរទាំងអស់មកឃើញអគារនេះ ដោយវានឹងធ្វើឲ្យអ្នកទស្សនាមានអារម្មណ៍ថាស្រឡាញ់ជាតិជាងមុន”។















បណ្ណាល័យសម្តេចម៉ែ គឺមិនមែនគ្រាន់តែជាទីតាំងសម្រាប់សិក្សាអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាតែប៉ុណ្ណោះនោះទេ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានមោទកភាពក្នុងការថ្វាយ និងជូនបណ្ណាល័យនេះជាកេរដំណែលរបស់សម្តេចម៉ែ និងស្ត្រីកម្ពុជាគ្រប់រូប។ ស្ត្រីកម្ពុជាបានខិតខំប្រឹងប្រែង ដោយមិនរួញរាក្នុងការស្តារ លើកស្ទួយ និងកសាងប្រទេសជាតិសារជាថ្មី តាមរយៈការចិញ្ចឹមបីបាច់គ្រួសារ ក្តាប់យកនិងពង្រីកឱកាសសេដ្ឋកិច្ច អភិរក្ស ការពារ និងពង្រឹងសហគមន៍ វប្បធម៌ និងប្រទេសជាតិរបស់ខ្លួន ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នេះសបញ្ជាក់ឲ្យឃើញថាស្ត្រីកម្ពុជា គឺជានិមិត្តរូប នៃដួងព្រលឹងជាតិកម្ពុជា។ បណ្ណាល័យសម្តេចម៉ែ បង្កើតឡើងដើម្បីឧទ្ទិសដល់ស្ត្រីកម្ពុជាទាំងនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

# អូស្ត្រាលី





លោកឯកអគ្គរាជទូត ប៉ាប្លូ កាង តំណាងឲ្យស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានដឹកនាំក្រុមការងាររបស់លោកធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០។

បន្ទាប់ពីសម្តែងការរីករាយទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះប្រតិភូកិត្តិយស លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងាររបស់លោក បានធ្វើបទបង្ហាញយ៉ាងលម្អិតអំពីពិព័រណ៌សំខាន់ៗទាំងពីររបស់ «បណ្ណាល័យសម្តេចម៉ែ» គឺ ពិព័រណ៌អំពីព្រះឆាយាលក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងពិព័រណ៌អំពីប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹត។ លោកស្រី សូ ហ្វារីណា បានណែនាំដល់ភ្ញៀវកិត្តិយសអំពីមជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្ណាល័យឯកសារខ្មែរក្រហមនៅតាមបណ្តាខេត្តទាំង៦។

លោក ឆាំង យុ ក៏បានបង្ហាញដល់ប្រតិភូនូវបណ្ណាល័យសម្តេចម៉ែ ដែលមានផ្ទុកឯកសារប្រមាណជាង ១,៧លានសន្លឹកនិងបណ្ណសារក្នុងទម្រង់ផ្សេងៗ ប្រមែប្រមូលដោយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា អស់រយៈពេលជាង២៥ឆ្នាំកន្លងមក ព្រមទាំងបណ្ណសារថ្មីបន្ថែមទៀត ដែលជាការបរិច្ចាគដ៏សប្បុរសរបស់ឯកអគ្គរាជទូត បណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីចុងឆ្នាំ២០១៩។

សមុច្ច័យដែលឯកអគ្គរាជទូតបណ្ឌិត ដែលជ្រេស រួមបញ្ចូល សៀវភៅកំណត់ហេតុ ឯកសារផ្ទាល់ខ្លួន និងឯកសារការទូតជាច្រើនអនេកស្តីពីប្រវត្តិសាស្ត្រនាពេលថ្មីៗរបស់កម្ពុជា ដែលបានមកពីប្រទេសអូស្ត្រាលីនិងប្រទេសដទៃទៀត។ សមុច្ច័យខាងលើ ក៏រួមមាន ស៊ីឌីថាសចម្រៀង និងឯកសារក្នុងទម្រង់ផ្សេងៗដែលមានទម្ងន់សរុបជាង១៥៨០គីឡូក្រាម។ សមុច្ច័យទាំងអស់គឺសុទ្ធសឹងជាសមិទ្ធផលនៃការចងក្រងឯកសារនិងការស្រាវជ្រាវផ្ទាល់ខ្លួនរបស់លោកឯកអគ្គរាជទូតបណ្ឌិត ដែលជ្រេស ក្នុងរយៈកាលជាច្រើនទសវត្សរ៍កន្លងមក។

គួររំឭកថា លោកឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស ជាជនជាតិអូស្ត្រាលី មានដើមកំណើតនៅប្រទេសឈីលី។ លោក គឺជាលេខាផ្ទាល់របស់ទ្រង់ចាប់ពីឆ្នាំ១៩៨១រហូតដល់ឆ្នាំ១៩៩១ និងគឺជាអតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ ចាប់តាំងពីឆ្នាំ១៩៩៣។ លោកឯកអគ្គរាជទូត បានបោះពុម្ពស្នាដៃស្រាវជ្រាវជាច្រើនទាក់ទងនឹងព្រះរាជវង្សានុវង្សកម្ពុជា និងព្រមទាំងបន្តកិច្ចការស្រាវជ្រាវបន្ថែមទៀតរបស់លោកលើប្រធានបទខាងលើ។

លោក ឆាំង យុ បានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការបរិច្ចាគដ៏ថ្លៃថ្លារបស់លោកឯកអគ្គរាជទូតបណ្ឌិត លោកបានលើកឡើងថា៖ "ការបរិច្ចាគនេះមិនមែនត្រឹមតែជាអំណោយផ្នែកចំណេះដឹងដ៏វិសេស













វិសាលមួយប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជាការបរិច្ចាគមួយ សម្រាប់អនាគតនៃការអប់រំនិងការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាដែរ”។ លោកបានបន្តថា បណ្ណាល័យ សាលារៀន និងមជ្ឈមណ្ឌលឯកសារស្រាវជ្រាវសព្វថ្ងៃ គឺជា “ថ្នាលបណ្តុះគ្រាប់ពូជសម្រាប់អនាគតនៃប្រទេសកម្ពុជា”។

តាមរយៈទស្សនកិច្ច និងកិច្ចពិភាក្សាលើប្រធានបទនានាជុំវិញការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រតិភូបានបង្ហាញអំពីការកោតសរសើរ និងសេចក្តីពេញចិត្តយ៉ាងក្រៃលែង។ តំណាងឲ្យប្រតិភូកិត្តិយស និងស្ថានទូតអូស្ត្រាលី លោកឯកអគ្គរាជទូត ប៉ាប្លូ កាង បានផ្តល់ជាចំណារអនុស្សាវរីយ៍លើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានសេចក្តីដូចតទៅ៖

**“នេះជាកិត្តិយស និងបទពិសោធន៍ដ៏ប្រសើរសម្រាប់រូបខ្ញុំ និងបុគ្គលិករបស់ខ្ញុំ ដែលបានមកទស្សនា បណ្ណាល័យសម្តេចម៉ែ និងបានស្តាប់ព័ត៌មានលម្អិតបន្ថែមអំពីការងារដ៏មានសារសំខាន់បន្តបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការចងក្រងប្រវត្តិសាស្ត្រកម្ពុជា សិក្សាពីអតីតកាល និងសញ្ជឹងទៅកាន់អនាគតប្រកបដោយភាពវិជ្ជមាន។ ខ្ញុំក៏មានសេចក្តីស្ងប់ស្ងែងដោយបានដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយនឹងស្ថាប័នសិក្សា និងនិស្សិតអន្តរជាតិជាច្រើន។ ខ្ញុំរំពៃចំពោះការចូលរួមយ៉ាងសស្រាក់សស្រាំពីស្ថានទូតរបស់យើងនាពេលអនាគតដ៏ខ្លីខាងមុខ”។**

# ទួរគី



លោកស្រី អៃដា អ៊ិនលូ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគីប្រចាំនៅកម្ពុជា បានធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នារសៀលថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០។ ថ្វីបើអាកាសធាតុមិនអំណោយផលដោយមានភ្លៀងធ្លាក់ជន់ជោរ និងបញ្ហាជំងឺកូវីដ១៩ លោកស្រីឯកអគ្គរដ្ឋទូត អៃដា អ៊ិនលូ នៅតែបំពេញដំណើរទស្សនកិច្ចនេះ ដើម្បីបង្ហាញអំពីការទទួលស្គាល់និងគាំទ្រចំពោះ «បណ្ណាល័យសម្តេចម៉ែ»។

សាធារណរដ្ឋតួកគី ជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេសទាំង១២ នៅតំបន់មជ្ឈិមបូព៌ា។ មជ្ឈិមបូព៌ាគឺជាតំបន់មួយដែលពោរពេញទៅដោយធនធានធម្មជាតិរ៉ែប្រេងកាតដ៏ស្តុកស្តម្ភ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ មជ្ឈិមបូព៌ាមានទំនាស់ប្រឈមមុខដាក់គ្នាឥតឈប់ឈររវាងបណ្តាប្រទេសក្នុងតំបន់ និងក្រៅតំបន់។ នៅក្នុងនោះរួមមានបញ្ហាចម្រុះជាតិសាសន៍ ដែលបណ្តាលឲ្យកើតសង្គ្រាម, ជម្លោះសាសនា, បញ្ហាផ្ទៃក្នុងប្រទេស និងបញ្ហាគោលនយោបាយរបស់ប្រទេសមហាអំណាចប្រជែងគ្នាក្នុងការគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្លាប់បានបំពេញការងារនៅតំបន់មជ្ឈិមបូព៌ា។ កាលពីជាង១០ឆ្នាំមុន លោក ឆាំង យុ បានបំពេញបេសកម្មនៅប្រទេសអ៊ីរ៉ាក់ ក្នុងការប្រមែប្រមូលភ័ស្តុតាងបទឧក្រិដ្ឋកម្មអន្តរជាតិនានាដែលជាឯកទេសរបស់លោក ដើម្បីចូលរួមក្នុងដំណើរការរៀបចំតុលាការកាត់ទោសអតីតប្រធានាធិបតីអ៊ីរ៉ាក់ គឺលោក សាដាម ហ៊ូសេន។

ក្នុងដំណើរទស្សនកិច្ចមកកាន់«បណ្ណាល័យសម្តេចម៉ែ» ក្នុងថ្ងៃនេះ លោកស្រី អ៊ិនលូ មានសេចក្តីពេញចិត្តយ៉ាងខ្លាំងចំពោះកិច្ចការងារចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកស្រីបានបង្ហាញចំណាប់អារម្មណ៍ជាពិសេសលើប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹត ដែលជាស្នាដៃរបស់ស្ថាបត្យកររកម្រិតពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ មានកំណើតនៅប្រទេសអ៊ីរ៉ាក់មានសញ្ជាតិជាអង់គ្លេសដែលមានភាពខុសប្លែកពីគំរូបែបអភិរក្សនៃសំណង់ស្ថាបត្យកម្ម បម្រើនាទីជាបូជនីយដ្ឋានរំឭកពីអំពើប្រល័យពូជសាសន៍ ដែលធ្លាប់សាងសង់កាលពី៧០ឆ្នាំមុនមក។ អគារវិទ្យាស្ថានស្លឹករឹត គឺជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីរំឭក និងឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតប្រមាណ២លាននាក់ នារអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។











ស្ថាបត្យកម្មបែបពត់ពេន ប៉ុន្តែមានឥទ្ធិពលរបស់លោកស្រី ហ្សាហា ហាឌីដ ផ្តោតទៅលើរូបរាងបត់បែន ជាជាងរូបរាងមុតនិងមានសណ្ឋានធរណីមាត្របង្ហាញពីជ្រុងជាក់លាក់ ដែលប្រៀបដូចទៅនឹងអគារឧស្សាហកម្ម។ ស្នាដៃស្ថាបត្យកម្មរបស់លោកស្រីមានសក្តានុពលអាចកែប្រែគំនិតរចនានៃសំណង់ស្ថាបត្យកម្មបម្រើតួនាទីជាបូជនីយដ្ឋានរំឭកដល់ឧក្រិដ្ឋកម្មសង្គ្រាមឲ្យផ្លាស់មុខមាត់ថ្មីនិងប្រសើរជាងមុនៗ លើសពីនេះទៅទៀត ដោយសារតែជនរងគ្រោះស្លូតត្រង់នៃឧក្រិដ្ឋកម្មសង្គ្រាមតែងតែរួមមានស្ត្រីនិងកុមារជាច្រើន នេះគឺជាពេលវេលាដ៏ស័ក្តិសម ដែលស្ត្រីគួរតែដើរតួនាទីជាអ្នកដឹកនាំការងាររចនាបូជនីយដ្ឋាន ដើម្បីទទួលស្គាល់និងរំលេចនូវការបាត់បង់ជារួមរបស់ជនរងគ្រោះទាំងនោះ។

លោកស្រី អែដា អ៊ុនលូ បានបង្ហាញចំណាប់អារម្មណ៍យ៉ាងជ្រាវជ្រៅចំពោះបណ្ណាល័យសម្តេចម៉ែ។ នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ច លោកស្រី អែដា អ៊ុនលូ បានចារនូវសំណេរអនុស្សាវរីយ៍នៅលើសៀវភៅក្រាំងមាសរបស់សម្តេចម៉ែដែលមានខ្លឹមសារដូចខាងក្រោម៖

***«តំណាងឱ្យស្ថានទូតនៃសាធារណរដ្ឋតួកគី ព្រមទាំងរូបនាងខ្ញុំផ្ទាល់ សូមសម្តែងអំណរសាទរចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា និងវិទ្យាស្ថានស្ពឺកីរីតសម្រាប់កិច្ចខិតខំប្រឹងប្រែងដ៏ធំធេង ក្នុងការបង្កើតបណ្ណាល័យសម្តេចម៉ែ ដើម្បីថ្វាយព្រះរាជកិត្តិយសជូនសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ។***

***« នាងខ្ញុំជឿជាក់ថា បណ្ណាល័យសម្តេចម៉ែមិនត្រឹមតែជាចន្លោងបំភ្លឺអំពីប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងបន្តជាប្រភពដ៏មានតម្លៃសម្រាប់ការអប់រំរបស់សាធារណជន ក៏ដូចជាមនុស្សជំនាន់ក្រោយទៅមុខទៀត។ ខ្ញុំសូមសម្តែងនូវការដឹងគុណចំពោះលោក ឆាំង យុ និងឯកអគ្គរាជទូត ហ្វូលីយ៉ូ អេ. វែលរេជ្រស ដែលទទួលស្វាគមន៍នាងខ្ញុំមកកាន់ទីតាំងដ៏មានសារសំខាន់នេះ ក្នុងថ្ងៃនេះ» ។***

ដោយគ្មានមន្ទិលសង្ស័យ បណ្ណាល័យសម្តេចម៉ែ គឺជាធនធានជាតិដ៏មានសារសំខាន់ សម្រាប់ការអប់រំសាធារណជននិងយុវជននាពេលបច្ចុប្បន្ន និងជាច្រើនជំនាន់តទៅមុខទៀតនាពេលអនាគត។ មជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ទុកសុវត្ថិភាពសាធារណជាអាទិភាព។ ស្របពេលដែលពិភពលោកកំពុងប្រឈមនឹងវិបត្តិនៃជំងឺរាតត្បាត កូវីដ១៩ ឯសកម្មភាពអប់រំ សកម្មភាពវប្បធម៌ និងព្រឹត្តិការណ៍ជាតិផ្សេងៗនៅតែបន្ត មជ្ឈមណ្ឌលឯកសារកម្ពុជា ជឿជាក់ថាសកម្មភាពទាំងអស់នេះត្រូវតែប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងបានគិតគូរទុកជាមុនអំពីសុខភាពនិងសុខុមាលភាពរបស់មនុស្សគ្រប់រូប។ អាស្រ័យហេតុនេះហើយ នាខណៈពេលបច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជា សូមរក្សាសិទ្ធិអនុញ្ញាតឲ្យសាធារណជនចូលប្រើប្រាស់បណ្ណាល័យសម្តេចម៉ែ តាមប្រព័ន្ធអនឡាញ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា បញ្ហាជំងឺរាតត្បាតជាសកលនេះនឹងស្រាកស្រាន្តទៅនាពេលឆាប់ ហើយ «បណ្ណាល័យសម្តេចម៉ែ» អាចចាប់ផ្តើមទទួលសាធារណជនបានទូលាយជាងមុន។





# គុយបា



លោកស្រី លីយូរកា រ៉ូឌ្រីហ្គេល បារីយ៉ូស ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបាប្រចាំព្រះរាជាណាចក្រកម្ពុជា និងកូនស្រីរបស់លោកស្រី អាល់លីន រូដរីហ្គិស បារីយ៉ូស បានធ្វើទស្សនកិច្ចមកកាន់«បណ្ណាល័យសម្តេចម៉ែ»នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នារសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ដើម្បីបង្ហាញអំពីការទទួលស្គាល់ចំពោះវត្តមាននៃបណ្ណាល័យនេះ។



ក្នុងដំណើរទស្សនកិច្ចនេះ ប្រតិភូកិត្តិយសបានទស្សនាពិព័រណ៍សំខាន់ៗទាំងពីររបស់បណ្ណាល័យសម្តេចម៉ែ រួមមាន ព្រះឆាយាល័ក្ខណ៍សម្តេចព្រះបរមរតនកោដ្ឋ និងប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹត ព្រមទាំងបរិក្ខាររក្សាទុកនិងចងក្រងឯកសាររាប់សែនទំព័រ ដែលជាសមិទ្ធផលនៃការងារក្នុងរយៈកាលជាង ២៥ឆ្នាំកន្លងមករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកស្រីឯកអគ្គរដ្ឋទូត បានបង្ហាញចំណាប់អារម្មណ៍យ៉ាងជ្រាវជ្រៅចំពោះពិព័រណ៍ព្រះឆាយាល័ក្ខព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បន្ទាប់ពីលោកឯកអគ្គរដ្ឋទូតបណ្ឌិត ហូលីយ៉ូ អេ.ដែលជ្រេស ដែលជាអ្នកសរសេរជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋនរោត្តម សីហនុ រៀបរាប់អំពីព័ត៌មានពិស្តារជាភាសាអេស្ប៉ាញ។



នៅក្នុងខែមេសា ឆ្នាំ២០២០នេះ ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋគុយបា បានប្រារព្ធគម្រប់ខួបទី៦០នៃចំណងមិត្តភាពការទូតរបស់ខ្លួន។ ទំនាក់ទំនងរវាងប្រទេសទាំងពីរបានកើតមានឡើងចាប់តាំងពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៦០មកម្ល៉េះ។ ទំនាក់ទំនងជាប្រវត្តិសាស្ត្រមួយនេះគឺចាប់ផ្តើមចេញពីទិសដៅស្របគ្នានៃប្រទេសទាំងពីរ គឺ កម្ពុជានិងគុយបា ក្រោមការដឹកនាំរបស់ សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងលោក ហ៊្វីដែល កាស្ត្រូ រូហ្ស ដោយប្រកាន់យកនូវគោលនយោបាយមិនចូលបក្សសម្ព័ន្ធដូចគ្នា នៅអំឡុងពេលសង្គ្រាមត្រជាក់រវាងប្លុកកុម្មុនីស្តនិងប្លុកសេរី។











ថ្វីត្បិតតែសាធារណរដ្ឋគុយបាមានទីតាំងភូមិសាស្ត្រនៅទ្វីបអឺរ៉ុប ឯកម្ពុជាស្ថិតនៅទ្វីបអាស៊ីក្តី ចម្ងាយភូមិសាស្ត្រនេះ មិនបានបង្កជាការរអាក់រអួលដល់ទំនាក់ទំនងរវាងប្រទេសទាំងពីរទេ។ ប្រទេសទាំងពីរនៅតែមានភាពជិតស្និទ្ធនឹងគ្នា ហើយបច្ចុប្បន្នប្រទេសទាំងពីរក៏បានប្រកៀកស្មាគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩។ ជាក់ស្តែង នៅក្នុងសំណេរថ្លែងអំពីចំណងមិត្តភាពនៃប្រទេសកម្ពុជានិងគុយបា ដើម្បីអបអរគម្រប់ខួបលើកទី៦០ លោកស្រីឯកអគ្គរដ្ឋទូត បានលើកឡើងថា៖ “យើងនឹងបន្តការងារក្នុងការរឹតចំណងសម្ព័ន្ធភាពរបស់យើង ហើយយើងប្រាកដថាចំណងមិត្តភាពរបស់យើងនឹងអាចតស៊ូប្រឆាំងនឹងគ្រប់ប្រភេទជំងឺទាំងអស់”។

តាមរយៈដំណើរទស្សនកិច្ច និងកិច្ចពិភាក្សាលើប្រធានបទនានាជុំវិញការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រតិភូកិត្តិយសបានបង្ហាញអំពីការគាំទ្រ និងការពេញចិត្តយ៉ាងក្រៃលែងចំពោះបណ្ណាល័យសម្តេចម៉ែ។ តំណាងឲ្យប្រតិភូកិត្តិយសនិងស្ថានទូតសាធារណរដ្ឋគុយបា លោកស្រី លីយូរកា រ៉ូឌ្រីហ្គេស បារីយ៉ូស បានរក្សាទុកចំណារអនុស្សាវរីយ៍នៅលើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានសេចក្តីដូចតទៅ៖

---

**« នេះពិតជាកិត្តិយសសម្រាប់ខ្ញុំ និងកូនស្រីរបស់ខ្ញុំ អាលលីន ក្នុងការទទួលបានបទពិសោធន៍ដ៏វិសេសវិសាលមកកាន់ «បណ្ណាល័យសម្តេចម៉ែ»។ ក្នុងឱកាសនេះ យើងទាំងពីរអាចយល់ដឹងជាច្រើនអំពីប្រវត្តិសាស្ត្រនៃរាជវង្សានុវង្ស និងប្រជាជនកម្ពុជា។ ប្រទេសគុយបា និងកម្ពុជា បានប្រារព្ធខួបអនុស្សាវរីយ៍ទី៦០ នៃការបង្កើតសម្ព័ន្ធភាពការទូតរវាងប្រទេសទាំងពីរ។ ទស្សនកិច្ចនេះគឺជាផ្នែកមួយនៃការអបអរគម្រប់ខួបនេះ។**

**ពីខ្ញុំ លីយូរកា រ៉ូឌ្រីហ្គេល បារីយ៉ូស អគ្គរដ្ឋទូតសាធារណរដ្ឋគុយបាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងកូនស្រីរបស់ខ្ញុំ អាលលីន រ៉ូឌ្រីហ្គេល បារីយ៉ូស » ។**

---

# អតីតលេខាស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅទីក្រុងម៉ានីល ទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ»







*«ថ្ងៃនេះ ខ្ញុំ ហ៊ុល ថុនណាក់ និងប្អូនប្រុស លឹម ច័យធត្ត មានសេចក្តីសោមនស្សរីករាយ ដែលលោក ឆាំង យុ និងលោកបណ្ឌិត ហ្វូលីយ៉ូ បានផ្តល់កិត្តិយសឱ្យយើងខ្ញុំទាំងពីររូបមកទស្សនា «បណ្ណាល័យសម្តេចម៉ែ» ជាមួយនឹងការស្វាគមន៍យ៉ាងកក់ក្តៅ។*

*«បណ្ណាល័យសម្តេចម៉ែ» គឺជាឃ្លាំងឯកសារប្រវត្តិសាស្ត្រមួយ ដែលមិនអាចកាត់ថ្លៃបាន សម្រាប់កុលបុត្រ កុលធីតា ដើម្បីធ្វើការសិក្សាស្រាវជ្រាវនិងស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជា ជាពិសេសមន្ត្រីការទូតវ័យក្មេងដូចជាយើងខ្ញុំ។*

*ខ្ញុំជឿជាក់ថា បណ្ណាល័យនេះនឹងបម្រើផលប្រយោជន៍ជាតិ និងអន្តរជាតិ ក្នុងការស្វែងយល់ពីឫសគល់នៃសង្គ្រាម និងសន្តិភាព ដែលប្រទេសតូចដូចកម្ពុជាបានឆ្លងកាត់យ៉ាងលំបាក រហូតទទួលបានសន្តិភាពពេញលេញរហូតដល់មានពេលប្រមូលឯកសារមកពីគ្រប់ទីកន្លែង មកតម្កល់ក្នុងទីនេះ។ លើសពីនេះទៅទៀត ការរៀបចំបណ្ណាល័យដ៏មានសោភ័ណភាពនេះ បានមកពីការចំណាយគំនិតយ៉ាងជិតដល់របស់លោក ឆាំង យុ ហាក់ប្រកបដោយអារម្មណ៍ជ្រះថ្លារពេលចូលមកដល់ ពេលចូលមកអាន និងមកពិភាក្សាគ្នា។ ខាងផ្ទះបញ្ជាំងពីគំនិតឆ្លៃប្រឌិតលក្ខណៈបុរាណ និងសម័យទំនើបបញ្ចូលគ្នា ដែលអាចនិយាយថា «ខ្ញុំស្រឡាញ់ទីនេះ» ។*

*ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់លោកពូ ដែលទទួលស្វាគមន៍យើងខ្ញុំ និងសូមប្រសិទ្ធិពរជ័យដល់លោកពូ និងលោកបណ្ឌិត សូមសម្រេកបតែសុខភាពល្អ និងជោគជ័យរាល់ភារកិច្ចទាំងបច្ចុប្បន្ន និងអនាគត។ ពីខ្ញុំ ថុនណាក់ ។*

---

ខាងលើនេះគឺជាចំណារអនុស្សាវរីយ៍របស់កញ្ញា ហ៊ុល ថុនណាក់ អតីតលេខាស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅទីក្រុងម៉ានីល ដែលបានចារនៅលើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ក្នុងអំឡុងទស្សនកិច្ចរបស់ខ្លួនដើម្បីបង្ហាញអំពីការគាំទ្រចំពោះ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានារសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០។

គួររំឭកថា នេះគឺជាលើកទី២ ដែលលោក ឆាំង យុ និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍ភ្ញៀវកិត្តិយសពីក្រសួងការបរទេស

និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា។ ទស្សនកិច្ចលើកទី១ គឺជាការអញ្ជើញមកដល់របស់ស្ត្រីតំណាងក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១២រូប ក្រោមកិច្ចផ្តួចផ្តើមរបស់សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០។

នៅក្នុងអំឡុងពេលទស្សនកិច្ចប្រតិភូកិត្តិយស ទទួលជ្រាបអំពីព័ត៌មានលម្អិតស្តីពីពិព័រណ៍ព្រះឆាយាល័ក្ខណ៍សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងព្រះរាជវង្សានុវង្ស រៀបរាប់ដោយលោកឯកអគ្គរាជទូតបណ្ឌិត ហ្ជូលីយ៉ូ អេ. ជែលជ្រេស អតីតអ្នកសរសេរជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ។ ប្រតិភូក៏បានទស្សនាបណ្ណាល័យដែលមានផ្ទុកឯកសារសៀវភៅរាប់ពាន់ក្បាល, ឯកសាររាប់សែនសន្លឹក, រូបថត, ឯកសារសោតទស្សន៍ និងបណ្ណសារឌីជីថលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសយល់ដឹងអំពីអត្ថន័យនៃប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹត។ ប្រតិភូកិត្តិយសថែមទាំងបានស្គាល់អំពីទីតាំងស្រាវជ្រាវ, និងមជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្ណាល័យខ្មែរក្រហមនៅតាមបណ្តាខេត្តទាំង១០ បង្ហាញដោយលោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាថែមទៀតផង។

ថ្វីត្បិតតែនាពេលបច្ចុប្បន្ន ស្ត្រីជាច្រើនបានចូលរួមនៅក្នុងមុខតំណែងសង្គម និងក្នុងវិស័យនានាជាច្រើនក្តី ស្ត្រីនៅតែពើបប្រទះនឹងបញ្ហាប្រឈមមួយចំនួននៅក្នុងមុខងាររបស់ខ្លួន។ ក្នុងនាមជាស្ត្រីមួយរូបដែលបម្រើការនៅក្នុងវិស័យការទូតផ្ទាល់ កញ្ញា ជុនណាក់ បានចែករំលែកថា៖ «មានបញ្ហាមួយចំនួនដែលមន្ត្រីការទូតជាស្ត្រីងាយប្រឈម ក្នុងនោះរួមមាន ចំណេះដឹងផ្នែកការទូតព្រោះថាតួនាទីទាំងនេះហាក់នៅថ្មីសម្រាប់ស្ត្រី, បន្ទុកក្នុងគ្រួសារ ដែលជាហេតុបណ្តាលឲ្យស្ត្រីមានផលពិបាកច្រើនពេលទៅធ្វើការនៅក្រៅប្រទេសឃ្លាតឆ្ងាយពីក្រុមគ្រួសារ, និងនៅលើឆាកអន្តរជាតិស្ត្រីទទួលរងនូវការរើសអើងដោយសារតែផ្នត់គំនិតនៅក្នុងសង្គមតែងតែប្រកាន់ថា មានតែមនុស្សប្រុសទើបអាចដឹកនាំប្រទេសបាន»។









# ប្រតិភូចំនួន ៤រូប ដឹកនាំដោយលោកស្រី រីបេកា កាង ដែលជាភរិយារបស់ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំនៅកម្ពុជាគឺលោក ផាប្លូ កាង បានធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ»



ប្រតិភូចំនួន៤រូប ដឹកនាំដោយលោកស្រី រីបេកា កាង ដែលជាភរិយារបស់ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំនៅកម្ពុជាគឺលោក ផាប្លូ កាង បានធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នាព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០។ ថ្វីបើអាកាសធាតុមិនអំណោយផល ដោយមានភ្លៀងធ្លាក់ជន់ជោរយ៉ាងណាក្តី ប្រតិភូកិត្តិយសនៅតែបំពេញដំណើរទស្សនកិច្ចនេះ។

នៅក្នុងអំឡុងពេលទស្សនកិច្ចរយៈពេលប្រមាណជាង២ម៉ោង លោក ឆាំង យុ និងក្រុមការងារបានទទួលគារវកិច្ចស្វាគមន៍ភ្ញៀវកិត្តិយសយ៉ាងយកចិត្តទុកដាក់ ព្រមទាំងផ្តល់បទបង្ហាញអំពីពិព័រណ៍ និងបរិក្ខាររបស់ «បណ្ណាល័យសម្តេចម៉ែ»។ លោកឯកអគ្គរាជទូតហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ បានរៀបរាប់ពិព័រណ៍ស្តីអំពីព្រះឆាយាលក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ ដែលតាំងបង្ហាញនៅបណ្ណាល័យសម្តេចម៉ែ។

ប្រតិភូកិត្តិយសបានចាប់អារម្មណ៍ទៅលើព្រះឆាយាលក្ខណ៍មួយផ្ទាំងរបស់សម្តេចព្រះបរមរតនកោដ្ឋ ដែលបង្ហាញអំពីព្រះរាជសកម្មភាពរបស់ទ្រង់កំពុងកាប់ដីដាក់បង្គី។ ព្រះឆាយាលក្ខណ៍មួយផ្ទាំងនេះ បានឆ្លុះបញ្ចាំងអំពីព្រះរាជសកម្មភាពដឹកនាំរបស់ព្រះអង្គក្នុងការកសាងជាតិ ដោយការស្ម័គ្រព្រះកាយចូលរួមបំពេញព្រះរាជកិច្ចជាមួយនឹងប្រជាជនកម្ពុជានាអំឡុងទសវត្សរ៍ទី៦០ ក្រោយពីប្រទេសកម្ពុជាទទួលបានឯករាជ្យ ដោយមិនប្រកាន់ព្រះកាយថាទ្រង់ជាក្សត្រឡើយ។

គួររំឭកថាកាលពីថ្ងៃម្សិលមិញនេះ គឺជាថ្ងៃប្រារព្ធខួបលើកទី៨នៃការកាន់ទុក្ខការយាងចូលទិវង្គតរបស់សម្តេចព្រះបរមរតនកោដ្ឋ ដោយទ្រង់បានសោយ

ទិវង្គតនាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ នៅមន្ទីរពេទ្យទីក្រុងប៉េកាំង ក្នុងព្រះជន្មាយុ៨៩ព្រះវស្សា។ ព្រះអង្គគឺជាឥស្សរជនដ៏ល្បីល្បាញនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ ទ្រង់ប្រសូត្រនៅរាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២។ ព្រះអង្គគឺជាព្រះរាជបុត្ររបស់សម្តេចព្រះ នរោត្តម សុរាម្រិត និងព្រះមហាក្សត្រី ស៊ីសុវត្ថិ កុសមៈ។

បន្ទាប់ពីឡើងសោយរាជ្យព្រះអង្គបានធ្វើចលនាតស៊ូដោយសន្តិវិធីក្នុងការទាមទារឯករាជ្យពីបារាំងដែលបានដាក់អាណាព្យាបាលមកលើប្រទេសកម្ពុជាតាំងពីឆ្នាំ១៨៦៣ រហូតទាល់តែបារាំងយល់ព្រមក្នុងការប្រគល់ឯករាជ្យពិតប្រាកដដល់ប្រទេសកម្ពុជានៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ក្រោយមកព្រះអង្គទ្រង់បានដឹកនាំប្រទេសដោយបង្កើតជា «របបសង្គម-រាស្ត្រនិយម»។ ក្រោមព្រះរាជគ្រប់គ្រងដឹកនាំរបស់ព្រះអង្គប្រទេសកម្ពុជាមានការរីកចម្រើនទៅលើវិស័យដូចជា សិក្សាធិការ, សុខាភិបាល, ឧស្សាហកម្ម និងយុត្តាធិការ ជាពិសេសកម្រិតជីវភាពសមរម្យរបស់មន្ត្រីរាជការ។ ព្រះអង្គត្រូវបានប្រជារាស្ត្រខ្មែរគោរពស្រឡាញ់ និងចាត់ទុកជាព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ។

ពេញមួយព្រះជីវិតរបស់ទ្រង់ សម្តេចព្រះបរមរតនកោដ្ឋ បានប្តូរផ្តាច់និងពលីដើម្បីជនរួមជាតិរបស់ទ្រង់។ ទ្រង់ចាត់ទុកសុខទុក្ខរបស់ប្រជាជនដូចទៅនឹងសុខទុក្ខរបស់ទ្រង់។ ទ្រង់បានយកព្រះទ័យទុកដាក់ជាខ្លាំងចំពោះជនរួមជាតិ ដោយទ្រង់តែងចុះសួរសុខទុក្ខ និងនាំយកនូវអំណោយប្រទានដល់ប្រជាជនទីទាល់ក្រនិងរងគ្រោះដោយគ្រោះធម្មជាតិនានា។ ព្រះកាយវិការដ៏ប្រពៃនេះ បានបន្តអនុវត្តដោយសម្តេចម៉ែ និងព្រះរាជវង្សានុវង្សរហូតមកដល់សព្វថ្ងៃ។

បច្ចុប្បន្ន ប្រជាជនកម្ពុជាភាគច្រើនកំពុងប្រឈមនឹងគ្រោះទឹកជំនន់។ ផ្ទះសម្បែងរាប់រយខ្នងត្រូវបានលិចលង់។ ថ្វីត្បិតតែសម្តេចម៉ែនិងសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា កំពុងពិនិត្យព្រះរាជសុខភាពនៅឯទីក្រុងប៉េកាំង













ទ្រង់នៅតែយកព្រះទ័យទុកដាក់លើប្រជាជនរបស់ទ្រង់។ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ កន្លងទៅនេះ ក្រោមព្រះរាជហឫទ័យទុកដាក់ខ្ពស់អំពីសុខទុក្ខរបស់បងប្អូនប្រជានុរាស្ត្រនិងខ្វល់ខ្វាយជានិច្ច អំពីបញ្ហាគ្រោះទឹកជំនន់ដែលកំពុងកើតមានតាមបណ្ដាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រកម្ពុជានិងសម្ដេចម៉ែ ស្ដេចសព្វព្រះរាជហឫទ័យត្រាស់បង្គាប់ក្រុមមន្ត្រីនៃក្រសួងព្រះបរមរាជវាំងនាំយកព្រះរាជអំណោយរបស់ព្រះអង្គទាំងទ្វេ ចែកជូនប្រជារាស្ត្ររងគ្រោះដោយទឹកជំនន់ចំនួន ៦៤៥គ្រួសារ ស្ថិតក្នុងខេត្តពោធិ៍សាត់។

ប្រតិភូបានធ្វើការពិភាក្សាទៅលើប្រធានបទមួយចំនួនទៀតប្រកបដោយអត្ថន័យគួរឲ្យកត់សម្គាល់ រួមមាន បញ្ហាសង្គម និងសុខាភិបាលរបស់ប្រជាជនកម្ពុជាដែលកំពុងពើបប្រទះនាពេលបច្ចុប្បន្ននេះ។

បន្ទាប់ពីដំណើរទស្សនកិច្ចដ៏មានខ្លឹមសារមកកាន់ «បណ្ណាល័យសម្ដេចម៉ែ» នេះ លោកស្រី រីបេកា កាង តំណាងឲ្យប្រតិភូកិត្តិយសបានចារចំណារអនុស្សាវរីយ៍ដែលមានអត្ថន័យដូចតទៅ៖

---

***«សូមអរគុណយ៉ាងអនេក ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានយល់ដឹងអំពីការងារដ៏អស្ចារ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលកំពុងបំពេញ ក្នុងការអភិរក្សប្រវត្តិ-សាស្ត្រប្រទេសកម្ពុជា និងគាំពារដល់ប្រជាជនកម្ពុជាដែលរងផលប៉ះពាល់ពីប្រវត្តិសាស្ត្រនេះ។ ដំណើរទស្សនកិច្ចនេះ គឺជាអំណោយ កិត្តិយស និងសេចក្ដីអំណរសម្រាប់យើងខ្ញុំ ក្នុងការមកកាន់ «បណ្ណាល័យសម្ដេចម៉ែ» ដ៏វិសេសវិសាលនេះ។ សូមប្រសិទ្ធិពរជ័យដល់ការងារបន្តបន្ទាប់របស់អ្នក។ ពីខ្ញុំ រីបេកា កាង, ភរិយារបស់លោកឯកអគ្គរាជទូតអូស្ត្រាលី» ។***

---

# បារាំង







លោកស្រី អេវ៉ា ង្វៀន ប៊ិញ ឯកអគ្គរដ្ឋទូតនៃស្ថានទូតបារាំងប្រចាំនៅកម្ពុជាបានដឹកនាំគណៈប្រតិភូចំនួន១៧រូប មកធ្វើទស្សនកិច្ចនៅការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និង «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

ប្រទេសបារាំង គឺជាប្រទេសមួយដែលគាំទ្រក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម។ បើគិតមកដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ បារាំងបានផ្តល់ថវិកាចំនួន៩,៨៨លានដុល្លារសហរដ្ឋអាមេរិកនៅក្នុងដំណើរការកាត់ទោសនេះ។

ភាសាបារាំង ក៏មានតួនាទីសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ ឯកសារទាក់ទងនឹងរបបខ្មែរក្រហមមួយចំនួន រួមទាំងសៀវភៅ និងព្រឹត្តិបត្រ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាភាសាបារាំង។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបកប្រែសៀវភៅប្រវត្តិសាស្ត្រធំមួយ កម្រាស់៥៤៩ទំព័រដែលមានចំណងជើងថា «HISTOIRE DU CAMBODGE: Depuis Le 1er Siècle de Notre Ère Adhemard Leclère» (ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់តាំងពីទសវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក) ពីភាសាបារាំងមកជាភាសាខ្មែរ ហើយបានចែកជូនសិស្សានុសិស្សព្រមទាំងគរុសិស្សនៅទូទាំងប្រទេសកម្ពុជារហូតមកទល់សព្វថ្ងៃនេះ។ សៀវភៅប្រវត្តិសាស្ត្រកម្ពុជានេះ គឺជាឯកសារក្បោះក្បាយ និងមានសារប្រយោជន៍យ៉ាងខ្លាំង ក្នុងការជួយដល់អ្នកសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាបច្ចុប្បន្ន។

មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយសិល្បករ សេរ៉ា អ៊ីង ក្នុងការសាងសង់រូបចម្លាក់ដើម្បីរំឭកការចងចាំអំពីជនរងគ្រោះនៃរបបខ្មែរក្រហម ដែលទទួលបានជំនួយឧបត្ថម្ភពីស្ថានទូតបារាំងប្រចាំនៅកម្ពុជា និងជាផ្នែកមួយនៃគម្រោងសំណង់របស់តុលាការខ្មែរ











ក្រហម។ រូបចម្លាក់នេះមានឈ្មោះថា «សម្រាប់អ្នកដែលលែងនៅទីនេះទៀតហើយ» ដែលបច្ចុប្បន្នត្រូវបានដាក់តាំងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

ជាកិច្ចចាប់ផ្តើមនៃដំណើរទស្សនកិច្ច ភ្ញៀវកិត្តិយសបានធ្វើដំណើរមកកាន់ការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាទីតាំងចងក្រង និងរក្សាទុកឯកសារពីសម័យខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារជាង ៥សែនឯកសារទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកស្រី សូ ហ្វារីណា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញដល់ប្រតិភូអំពីការងារបច្ចុប្បន្នរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានទីតាំងចំនួន ១០ បាននិងកំពុងបន្តអនុវត្តនៅទូទាំង

ប្រទេសកម្ពុជា។ លោកស្រីក៏បានបកស្រាយអំពីកេរដំណែលស្នូលទាំងពារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមមានយុត្តិធម៌, ការចងចាំ និងការផ្សះផ្សា។

បន្ទាប់មក លោក ឆាំង យុ បាននាំប្រតិភូកិត្តិយសបន្តធ្វើទស្សនកិច្ចទៅកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអគារមួយសាងសង់ឡើងក្នុងឆ្នាំ ១៩២៥ នាអំឡុងសម័យអាណាព្យាបាលបារាំង។ ប្រជាជនទូទៅតែងតែហៅសំណង់ស្ថាបត្យកម្មប្រភេទខាងលើថាជា «ផ្ទះបារាំង» ដោយសារតែសំណង់ទាំងនេះសាងសង់ឡើងតាំងពីមុនពេលប្រទេសកម្ពុជាទទួលបានឯករាជ្យ។ អ្នកសិក្សាមួយចំនួនបានលើកឡើងថា «ផ្ទះទម្រង់បែបនេះ គឺជាផ្ទះខ្មែរក្នុងជំនាន់អាណាព្យាបាលបារាំង»។ លោក ឆាំង យុ បានរចនាកែលម្អអគារបណ្ណាល័យតាមបែបសហសម័យ ដោយរក្សាទុកនូវទម្រង់ទ្រាយដើម ដើម្បីបង្កើនសោភ័ណភាពឲ្យបានស័ក្តិសមនឹងព្រះបរមនាមរបស់សម្តេចម៉ែ។

លោក ឆាំង យុ និងលោកបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរជីវប្រវត្តិសម្តេចព្រះបរមរតនកោដ្ឋ បានផ្តល់ព័ត៌មានយ៉ាងពិស្តារ អំពីពិព័រណ៍ចម្បងចំនួនពីរគឺ ព្រះឆាយាលក្ខណ៍សម្តេចព្រះបរមរតនកោដ្ឋ និងការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹតរបស់លោកស្រី ហ្សាហា ហាឌីដ ដែលជាស្ថាបត្យករស្ត្រីដ៏កម្រនិងល្បីល្បាញកម្រិតពិភពលោក។ វិទ្យាស្ថានស្លឹករឹត គឺជាកេរដំណែលនៃការផ្សះផ្សាដែលមជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងទុកថា នឹងអាចមានការគាំទ្រសាងសង់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់មក ប្រតិភូកិត្តិយសបានទស្សនាបរិក្ខារតម្កល់ទុក និងអភិរក្សឯកសាររបស់ «បណ្ណាល័យសម្តេចម៉ែ»។ នៅចុងបញ្ចប់ ប្រតិភូកិត្តិយស និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានពិភាក្សាលើប្រធានបទស្តីពីសំណងជនរងគ្រោះនៃរបបខ្មែរក្រហម និងឯកសារដែលបន្សល់ទុកក្រោយពេលតុលាការបញ្ចប់ប្រតិបត្តិការ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា នឹងអាចបន្តការងារកាន់តែស្អិតរមួតជាមួយនឹងរដ្ឋាភិបាលបារាំងក៏ដូចជាស្ថានទូតបារាំងប្រចាំនៅកម្ពុជា ក្នុងការប្រមែប្រមូលឯកសារបន្តទៀត និងថែរក្សាទុកឯកសារតុលាការខ្មែរក្រហមក្រោយពេលដែលតុលាការនេះបញ្ចប់ទៅ។



នៅក្នុងកិច្ចពិភាក្សា អ្នកចូលរួមបានលើកឡើងអំពីគម្រោងថែទាំសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ប្រជាជនកម្ពុជាដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបមានចំនួនប្រមាណ ៥ លាននាក់។ បច្ចុប្បន្ន ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមគ្រូពេទ្យ និងគិលានុបដ្ឋាយិកាមកពីប្រទេសហ្វីលីពីន ក្នុងការផ្ដល់សេវាថែទាំសុខភាពផ្លូវកាយជូនដល់អ្នករស់រានមានជីវិតទាំងអស់នេះនៅតាមភូមិឋានមួយចំនួន។

លោកស្រីឯកអគ្គរដ្ឋទូត អេវ៉ា ង្វៀង ប៊ិញ តំណាងឲ្យប្រតិភូកិត្តិយស និងស្ថានទូតបារាំងនៅកម្ពុជា បានចារចំណារអនុស្សាវរីយ៍លើសៀវភៅក្រាំងមាស របស់ «បណ្ណាល័យសម្ដេចម៉ែ» ដែលមានអត្ថន័យដូចតទៅ៖

«ក្រុមការងាររបស់ខ្ញុំ និងរូបខ្ញុំផ្ទាល់សូមអរគុណយ៉ាងស្មោះស្ម័គ្រចំពោះលោក ឆាំង យុ និងក្រុមការងាររបស់លោក សម្រាប់ដំណើរទស្សនកិច្ចដ៏គួរឱ្យចាប់អារម្មណ៍ និងរំជួលចិត្តមួយនេះ។ នៅពីក្រោយដំណើរទស្សនកិច្ចខាងលើ មានការអនុវត្តការងារយ៉ាងសស្រាក់សស្រាំ ដើម្បីរក្សាការចងចាំ ការសិក្សាយល់ដឹង និងការចែករំលែកទៅកាន់អ្នកដទៃ ដែលនេះគឺជាកាយវិការដ៏មានតម្លៃបំផុត។ ខ្ញុំសូមសម្ដែងអំណរសាទរយ៉ាងក្រៃលែងចំពោះការងារដ៏មានសារប្រយោជន៍មហិមាសម្រាប់សង្គមជាតិកម្ពុជា»។






# ព្រុយណេ





លោក ដេនហ្គីរេន ខាស្មីហាន ដេនហ្គីរេន ថាហ៊ី ឯកអគ្គរាជទូតនៃស្ថានទូតព្រះរាជាណាចក្រព្រុយណេ ប្រចាំនៅកម្ពុជា បានធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

ព្រុយណេ គឺជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេសអាស៊ាន ដែលប្រកាន់របបរាជាធិបតេយ្យមានព្រះមហាក្សត្រគ្រងរាជ្យនិងកាន់អំណាច។ ព្រុយណេតែងតែផ្តល់ការគាំទ្រដោយប្រយោលជារៀងរហូតមកដល់ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការសិក្សាស្រាវជ្រាវទៅលើជនជាតិចាមនៅកម្ពុជា។

ប្រទេសព្រុយណេ គោរពប្រតិបត្តិសាសនាឥស្លាម។ គួររំឭកថា ចាប់តាំងពីចាប់បដិសន្ធិមកមជ្ឈ-មណ្ឌលឯកសារកម្ពុជាមានបុគ្គលិកកាន់សាសនាឥស្លាមសរុបប្រមាណ១៥ភាគរយនៃបុគ្គលិកទាំងអស់។ បុគ្គលិកដែលមានដើមកំណើតជាជនជាតិចាមមូស្លីមទាំងនេះបានធ្វើការសិក្សាស្រាវជ្រាវ សរសេរ និងបោះពុម្ពសៀវភៅផ្សេងៗទាក់ទងជាមួយនឹងសហគមន៍របស់ខ្លួន។ សៀវភៅ «ការចងចាំរបស់ស្ត្រីចាមមូស្លីមស្តីអំពីរឿងរ៉ាវក្នុងសម័យខ្មែរក្រហម» ដែលជាស្នាដៃនិពន្ធរបស់លោកស្រី សូ ហ្វារីណា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នដំបូងបង្អស់ដែលបានយកចិត្តទុកដាក់ និងធ្វើការជាមួយសហគមន៍ខ្មែរឥស្លាមចាប់តាំងពីឆ្នាំ១៩៩៥មកម្ល៉េះ តាមរយៈការស្រង់យកប្រវត្តិសាស្ត្រផ្ទាល់មាត់ដោយចុះទៅធ្វើការនៅតាម បណ្តាវិហារសាសនាឥស្លាមទាំងអស់នៅក្នុងប្រទេសកម្ពុជា។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារនានាដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីធ្វើការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម។ នៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ជនជាប់ចោទទាំងពីររូបត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងជនជាតិចាមស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត, ការបាត់ខ្លួនដោយបង្ខំ, ការសម្លាប់រង្គាល, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនិងសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ។

កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាមានកិច្ចសហការសិក្សាស្រាវជ្រាវជាមួយប្រទេសឥណ្ឌូនេស៊ី និងប្រទេសមីយ៉ាន់ម៉ា លើបញ្ហាសិទ្ធិមនុស្ស បញ្ហារើសអើងពូជសាសន៍ និងការសម្លាប់រង្គាល។











លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្លាប់បានបំពេញបេសកកម្មនៅប្រទេសអ៊ីរ៉ាក់ក្នុងការប្រមែប្រមូលភ័ស្តុតាងបទឧក្រិដ្ឋកម្មអន្តរជាតិនានា ដែលជាឯកទេសរបស់លោក ដើម្បីចូលរួមក្នុងដំណើរការរៀបចំតុលាការកាត់ទោសអតីតប្រធានាធិបតីអ៊ីរ៉ាក់គឺលោក សាដាម ហ៊ូសេន។

នៅក្នុងអំឡុងពេលទស្សនកិច្ចប្រមាណជាង ២ម៉ោង លោក ឆាំង យុ បានរៀបរាប់អំពីពិព័រណ៍ព្រះឆាយាលក្ខណ៍សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងព្រះរាជវង្សានុវង្ស, បន្ទប់បណ្ណាល័យដែលមានផ្ទុកសៀវភៅរាប់ពាន់ក្បាល, រូបថត, ឯកសារសោតទស្សន៍, បណ្ណសារឌីជីថលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ពិព័រណ៍ស្តីអំពីសាវតានិងអត្ថន័យនៃការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត និងការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹតរបស់លោកស្រី ហ្សាហា ហាឌីដ ដែលជាស្ថាបត្យករស្ត្រីដ៏ល្បីល្បាញនៅលើពិភពលោក។ ក្រៅពីនេះ លោកស្រី សូ ហ្វារីណា បានបង្ហាញអំពីទីតាំងស្រាវជ្រាវ, មជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្ណាល័យខ្មែរក្រហមនៅតាមបណ្តាខេត្តទាំង១០។ បន្ទាប់មកក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងភ្ញៀវកិត្តិយសបានពិភាក្សាគ្នាទៅលើបញ្ហាផ្សេងៗស្តីពីការប្រឈមនានារបស់ក្រុមជនជាតិភាគតិចនៅកម្ពុជា និងការថែរក្សាសន្តិភាពនៅក្នុងសហគមន៍មូលដ្ឋាន។

នៅចុងបញ្ចប់នៃដំណើរទស្សកិច្ចលោកឯកអគ្គរាជទូត ដេនហ្គីរេន ខាស្មីហាន ដេនហ្គីរេន ថាហ៊ីតំណាងឲ្យប្រតិភូកិត្តិយស និងស្ថានទូតព្រះរាជាណាចក្រ

*ព្រះយណោប្រចាំនៅកម្ពុជា បានផ្តល់ជាចំណារ អនុស្សាវរីយ៍លើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានសេចក្តីដូចតទៅ៖*



***« សូមអរគុណចំពោះបទពិសោធន៍ និងទស្សនកិច្ចដ៏អស្ចារ្យនេះ។ នេះគឺជាបទពិសោធន៍យ៉ាងពិសេសពិសាលសម្រាប់ខ្ញុំក្នុងការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងការដែលសម្តេចព្រះវររាជបិតាជាផ្នែកមួយដ៏សំខាន់នៃប្រវត្តិសាស្ត្រ។ ខ្ញុំសង្ឃឹមថាមជ្ឈមណ្ឌលឯកសារកម្ពុជា និងអាចអភិរក្សឯកសារ និងបណ្ណសារសម្រាប់មនុស្សជំនាន់ក្រោយ។ សារមន្ទីរនេះអាចនឹងមានទំហំតូច ប៉ុន្តែគឺជាសមុច្ច័យនៃបណ្ណសារដ៏ធំសម្បើមសម្រាប់អ្នករាល់គ្នាដែលចាប់អារម្មណ៍ក្នុងការសិក្សានិងស្រាវជ្រាវអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ជាពិសេសនៅក្នុងអំឡុងរបបខ្មែរក្រហម។ សូមអរគុណសាជាថ្មីម្តងទៀត » ។***



# សហរដ្ឋអាមេរិក



សហរដ្ឋអាមេរិក គឺជាប្រទេសដំបូងបង្អស់រួមជាមួយ និងរាជរដ្ឋាភិបាលកម្ពុជា ផ្តួចផ្តើមនិងគាំទ្រសាកលវិទ្យាល័យយ៉េល (Yale University) ឲ្យមានការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីខែមករា ឆ្នាំ១៩៩៥ មកម្ល៉េះ ដើម្បីស្រាវជ្រាវ និងចងក្រងឯកសារពីសម័យខ្មែរក្រហម(១៩៧៥-១៩៧៩) ក្នុងបុព្វហេតុយុត្តិធម៌ និងការចងចាំដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការផ្សះផ្សា និងថែរក្សាសន្តិភាពនៅកម្ពុជា។

ចាប់តាំងពីដំបូងមកទល់សព្វថ្ងៃនេះ សហរដ្ឋអាមេរិក និងបណ្តាប្រទេសដទៃទៀតនៅទ្វីបអឺរ៉ុប រួមទាំងអង្គការសហប្រជាជាតិបានផ្តល់ថវិកាជាបន្តបន្ទាប់ គាំទ្រការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ឆាំង យុ ដែលជាស្ថាបនិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាគឺជាអ្នកគាំទ្រយ៉ាងសំខាន់បំផុតនៅក្នុងដំណើរការស្រាវជ្រាវដ៏ស្មុគស្មាញមួយនេះ ជាពិសេសក្រសួងមហាផ្ទៃ និងលោកស្រី និន សាផុន ដែលត្រូវបានចាត់តាំងសហការដោយសម្តេចតេជោ និងបច្ចុប្បន្នគឺជាសមាជិកសភាជាតិ តែងតែផ្តល់ការគាំទ្រដល់មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រប់រូបភាពដោយវិជ្ជមាន និងឥតស្រាកស្រាន្តសោះឡើយ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមាន «បណ្ណាល័យសម្តេចម៉ែ» ស្ថិតនៅក្នុងទីក្រុងភ្នំពេញដើម្បីថ្វាយព្រះរាជកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជូនសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែលបានខិតខំប្រឹងប្រែងដើម្បីសម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ប្រទេសជាតិកម្ពុជា និងប្រជាជនកម្ពុជា។

ថ្ងៃនេះលោកឯកអគ្គរដ្ឋទូត ផាទ្រីក ម៉ូហ្វី និងភរិយាបានអញ្ជើញធ្វើទស្សនកិច្ចមកកាន់ «បណ្ណាល័យសម្តេចម៉ែ»។ លោកបានស្នើសុំឲ្យមានទស្សនកិច្ចជាលើកទី២ សម្រាប់បុគ្គលិកស្ថានទូតទាំងអស់នៅពេលក្រោយទៀត។ លោក ផាទ្រីក ធ្លាប់បានមានប្រសាសន៍នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងខេត្តឧត្តរមានជ័យ ដូចខាងក្រោមនេះថា៖ "សហរដ្ឋអាមេរិក គឺមានសេចក្តីសោមនស្សយ៉ាងក្រៃលែងជាដៃគូ និងជាអ្នកគាំទ្រ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងចងក្រងប្រវត្តិសាស្ត្រកម្ពុជា ថ្វីបើទំព័រប្រវត្តិសាស្ត្រនេះមានភាពស្មុគស្មាញយ៉ាងណាក្តី ព្រមទាំងបង្កើតការយល់ដឹងអំពីព្រឹត្តិការណ៍ដែលកើតមាននៅក្នុងអតីតកាល មិនឲ្យកើតមានឡើងសាជាថ្មីម្តងទៀត ជាពិសេស បន្តខិតខំប្រឹងប្រែងដើម្បីឈានទៅសម្រេចបាននូវសន្តិភាព និងការផ្សះផ្សា ក្នុងចំណោមប្រជាជន។ សហរដ្ឋអាមេរិក មានទិសដៅស្របគ្នាជាមួយនឹងកិច្ចខិតខំប្រឹងប្រែងនេះ"។

ដំណើរទស្សនកិច្ច ចាប់ផ្តើមដោយការរៀបរាប់យ៉ាងពិស្តារអំពីពិព័រណ៍នៃព្រះឆាយាល័ក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ, សម្តេចព្រះវររាជមាតាជាតិខ្មែរ និងរាជវង្សានុវង្សផ្តល់ដោយបណ្ឌិត ហ្ជូលីយ៉ូ អេ. ជែលជ្រេស អតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ អមជាមួយនឹងភ្លេងដែលជាព្រះរាជនិពន្ធរបស់សម្តេចព្រះបរមរតនកោដ្ឋ។

លោក ឆាំង យុ បានបង្ហាញដល់លោកឯកអគ្គរដ្ឋទូត និងភរិយានូវបណ្ណាល័យ ជាពិសេសគឺបណ្ណសារសោតទស្សន៍ ។ ឯកសារជាសំឡេងតម្កល់នៅបណ្ណាល័យសម្តេចម៉ែរួមមានបទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិត ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកសិក្សាស្រាវជ្រាវដទៃទៀតនៅជុំវិញពិភពលោកបានទៅជួបសម្ភាសន៍ក្នុងរយៈកាល៤០ឆ្នាំកន្លងមកនេះ។ យ៉ាងណាមិញ នៅមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយ៉ាងហោចណាស់បួនលាននាក់ទៀតមិនទាន់ត្រូវបានជួបសម្ភាសន៍ និងចងក្រងប្រវត្តិសាច់រឿងជីវិតពីសម័យខ្មែរក្រហមនៅឡើយ។













លោក ឆាំង យុ បានរៀបរាប់យ៉ាងលម្អិតអំពីសាវតា និងអត្ថន័យនៃប្លង់រចនារបស់អគារវិទ្យាស្ថានស្លឹករឹតរបស់លោកស្រី ហ្សាហា ហាឌីដ ដែលជាស្ថាបត្យករស្ត្រីដ៏ល្បីល្បាញ និងកម្រមួយរូប។ លោកស្រី សូ ហ្វារីណា បានបង្ហាញអំពីទីតាំងស្រាវជ្រាវ, មជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហមនៅតាមបណ្តាខេត្តទាំង១០ ដែលគឺជាផ្នែកមួយនៃគម្រោងអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៃគម្រោងសំណងតាមផ្លូវតុលាការ នៅក្នុងក្របខណ្ឌនៃសំណុំរឿង០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីឆ្នាំ២០១៣។

លោកឯកអគ្គរដ្ឋទូត និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានពិភាក្សាលើប្រធានបទមួយចំនួនស្តីអំពី ១) បញ្ហាសង្គមកិច្ច សុខភាពជនរងគ្រោះពីសម័យខ្មែរក្រហមនៅក្នុងរយៈកាលនៃជំងឺកូវីដ១៩ និងគ្រោះទឹកជំនន់ ២) ការប្រមែប្រមូលបទសម្ភាសន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលនៅសេសសល់ប្រមាណបួនលាននាក់ផ្សេងទៀត ៣) កិច្ចពិភាក្សាបានផ្តោតលើការអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដែលជាទីតាំងតស៊ូចុងក្រោយរបស់ខ្មែរក្រហមដើម្បីបង្កើនសក្តានុពលវិស័យទេសចរណ៍និងសេដ្ឋកិច្ចនៅក្នុងតំបន់ ព្រមទាំងថែរក្សាតំបន់ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងទីតាំងនេះ ឲ្យប្រកបដោយភាពឋិតថេរចីរកាលសម្រាប់មនុស្សជំនាន់ក្រោយ និង៤) ការងារអប់រំដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្ត។ គួររំឭកថា ចាប់តាំងពីឆ្នាំ២០០៧ ក្រោមជំនួយឧបត្ថម្ភដ៏សប្បុរសពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ មកទល់ពេលបច្ចុប្បន្នមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ព និងចែកចាយសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» និពន្ធដោយ ឌី ខាំបូលី និងក្រុមការងារចំនួនមួយលានក្បាលជូនអនុវិទ្យាល័យជាង១៧០០ ដែលភាគច្រើនស្ថិតនៅតំបន់ជនបទដាច់ស្រយាល។

លោក ឆាំង យុ បានលើកឡើងអំពីការរៀបចំការបោះពុម្ព និងការចែកចាយសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់ព្រមជាមួយនឹង

សៀវភៅសិក្សាសម្រាប់សិស្ស។ ទន្ទឹមនឹងនេះ គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា សម្រេចបានលទ្ធផលក្នុងការរៀបចំវេទិកាអប់រំសាធារណៈតាមវិទ្យាល័យចំនួន ៩៥០ និងបានរៀបចំសិក្ខាសាលានៅតាមសាកលវិទ្យាល័យជាង ២០០ នៅទូទាំងប្រទេសកម្ពុជា។ បន្ថែមលើសពីនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតនូវកម្មវិធីសិក្សាអប់រំ និងវគ្គបណ្តុះបណ្តាលគ្រូបង្រៀនជាង ៥០០០នាក់ ទៅលើផ្នែកប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ភូមិវិទ្យា និងសីលធម៌ ស្តីអំពីខ្លឹមសារ និងវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ កម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នេះបន្តនៅគ្រប់ការិយាល័យមូលដ្ឋានទាំង ១០ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

លោកឯកអគ្គរដ្ឋទូត ផាទ្រីក មូហ្វី តំណាងឲ្យស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាបានចារចំណារអនុស្សាវរីយ៍លើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានខ្លឹមសារដូចតទៅ៖

**« នេះគឺជាកិត្តិយសដ៏អស្ចារ្យក្នុងដំណើរទស្សនកិច្ចមកកាន់ "អ្នកជិតខាង" របស់ខ្ញុំ គឺ មជ្ឈមណ្ឌលឯកសារកម្ពុជា និងទស្សនាបណ្ណាល័យសម្តេចម៉ែថ្មីមួយប្រកបដោយសោភ័ណភាព ព្រមទាំងបានមើលឃើញបរិក្ខារតម្កល់ទុក និងវិភាគឯកសារសំខាន់ៗ ដែលរក្សាការចងចាំអំពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់ប្រទេសកម្ពុជា។ បណ្ណសារដែលតម្កល់ទុកនេះ បានរៀបចំយ៉ាងល្អប្រសើរ ដែលនឹងដើរតួនាទីជាធនធានស្រាវជ្រាវយ៉ាងសំខាន់សម្រាប់មនុស្សជំនាន់ក្រោយ។ សហរដ្ឋអាមេរិក មានសេចក្តីរីករាយក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងនេះ។ សូមអបអរសាទរដល់អ្នក និងថ្វាយអំណរសាទរទូលដល់សម្តេចម៉ែ។ - ផាទ្រីក មូហ្វី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា"។**





# ស៊ុយអែត








ស៊ុយអែត គឺជាប្រទេសមួយដែលបានជួយឧបត្ថម្ភដល់ប្រទេសកម្ពុជាភ្លាមៗ ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ២៨ឆ្នាំក្រោយមក លោក ថូម៉ាស់ ហាម៉ាប៊ឺក គឺជាជនជាតិស៊ុយអែតតំណាងឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានដឹកនាំការចរចា និងឈានទៅដល់កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក្នុងការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ លោក ឆាំង យុ បានមានប្រសាសន៍ថា៖ «ថ្វីត្បិតតែតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទទួលការរិះគន់ដ៏សមហេតុសមផលមួយចំនួនក្តី ប៉ុន្តែតុលាការនេះគឺជាសមិទ្ធិផលមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគួរឲ្យកត់សម្គាល់នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ»។

ប្រទេសស៊ុយអែត បន្តការគាំទ្រចេញពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅដល់ការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន និងនៅតាមមូលដ្ឋាន ព្រមទាំងការធានាឲ្យមាននូវកេរដំណែលនៃការផ្សះផ្សានិងគោរពសិទ្ធិមនុស្សថែមទៀតផង។ ប្រទេសស៊ុយអែត បានគាំទ្រដល់មជ្ឈមណ្ឌល





ឯកសារកម្ពុជាចាប់តាំងពីឆ្នាំ២០០០ រហូតមកដល់បច្ចុប្បន្ន។ នៅឆ្នាំ២០២០នេះ លោក ប៊ីចូន ហេកម៉ាគ ឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំនៅកម្ពុជា និងបុគ្គលិករបស់លោក អញ្ជើញទស្សកិច្ចនៅការិយាល័យកណ្ដាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និង «បណ្ណាល័យសម្ដេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ក្នុងអំឡុងទស្សនកិច្ចនៅការិយាល័យកណ្ដាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ភ្ញៀវកិត្តិយសបានជួបសំណេះសំណាលជាមួយបុគ្គលិក និងយល់ដឹងអំពីការងារទូទៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកស្រី សូ ហ្វារីណា បានបង្ហាញអំពីទីតាំងស្រាវជ្រាវ, មជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្ណាល័យខ្មែរក្រហម នៅតាមបណ្ដាខេត្តទាំង១០ ដែលគឺជាផ្នែកមួយនៃគម្រោងអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៃគម្រោងសំណងតាមផ្លូវតុលាការ នៅក្នុងក្របខណ្ឌនៃសំណុំរឿង០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីឆ្នាំ២០១៣។ បន្ទាប់មក ភ្ញៀវកិត្តិយសបានអញ្ជើញទៅកាន់ «បណ្ណាល័យសម្ដេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្ដេចព្រះបរមរតនកោដ្ឋ បានរៀបរាប់ជូនភ្ញៀវកិត្តិយសអំពី ១) ពិព័រណ៍សំខាន់ៗទាំងពីររបស់បណ្ណាល័យសម្ដេចម៉ែរួមមានពិព័រណ៍ព្រះឆាយាល័ក្ខណ៍របស់សម្ដេចព្រះបរមរតនកោដ្ឋ និងអត្ថន័យប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹតរបស់លោកស្រី ហ្សាហា ហាឌីដ ដែលជាស្ថាបត្យករល្បីល្បាញនិងកម្រមួយរូប និង២) បរិក្ខារនានានិងម៉ាស៊ីនផ្ទុកឯកសារជាទម្រង់ឌីជីថលរបស់បណ្ណាល័យសម្ដេចម៉ែ។

ម៉ាស៊ីនផ្ទុកឯកសារឌីជីថលមានផ្ទុកឯកសារជាង ១លាន៧សែនទំព័រ រួមមានឯកសារជាសន្លឹក រូបថតភាពយន្ត បទសម្ភាស និងឯកសារជាសំឡេងរបស់អ្នករស់រានមានជីវិតក្នុងសម័យខ្មែរក្រហម ដែលត្រូវបានធ្វើឲ្យមានគុណភាពខ្ពស់ ដើម្បីធានាដល់ការអភិរក្សលើឯកសារឲ្យបានគង់វង្ស។ បណ្ដុំឯកសារខាងលើត្រូវបានប្រមែប្រមូលមកពីច្រើនប្រភព ក្នុងនោះស៊ុយអែតក៏ជាអ្នកផ្គត់ផ្គង់ឯកសារពាក់ព័ន្ធដ៏សំខាន់ដែរ។



*នៅរយៈកាលចុងក្រោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តោតលើការបំលែងឯកសារ ដែលខ្លួនបានប្រមែប្រមូលចងក្រងអស់រយៈកាលជាង២៥ឆ្នាំទៅជាទម្រង់ឌីជីថល ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់សាធារណជន និងអ្នកស្រាវជ្រាវជាសកលឲ្យមានប្រសិទ្ធភាពជាងមុនៗ*

*នៅតាមការិយាល័យស្រាវជ្រាវនៅបណ្តាខេត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រៅពីឯកសារខ្មែរក្រហមក្នុងទម្រង់សន្លឹកផ្តោតជាពិសេសទៅលើតំបន់នីមួយៗ មជ្ឈមណ្ឌលឯកសារកម្ពុជា បានតម្លើងកុំព្យូទ័រនិងបរិក្ខារជួយសម្រួលដល់ការសិក្សាស្រាវជ្រាវដើម្បីអនុញ្ញាតឲ្យសាធារណជននិងអ្នកស្រាវជ្រាវអាចប្រើប្រាស់ឯកសារទូទៅដែលមានផ្ទុកនៅក្នុងម៉ាស៊ីនផ្ទុកឯកសារឌីជីថល តម្កល់ក្នុងបណ្ណាល័យសម្តេចម៉ែនៅឯរាជធានីភ្នំពេញ ពីតាមបណ្តាទីតាំងការិយាល័យទាំងនោះៗ ម៉ាស៊ីនផ្ទុកឯកសារបានជួយសម្រួលដល់ការតបនឹងសំណើបានឆាប់រហ័សនិងប្រសើរជាងមុនៗ មជ្ឈម-ណ្ឌលឯកសារកម្ពុជាកំពុងបន្តប្រមែប្រមូលបទសម្ភាសន៍និងឯកសារថ្មីៗបន្តទៀតនៅពេលបច្ចុប្បន្នៗ*

*លោកឯកអគ្គរដ្ឋទូត ប៊ីចូន ហេកម៉ាក តំណាងឲ្យប្រតិភូកិត្តិយស និងស្ថានទូតស៊ុយអែតប្រចាំនៅកម្ពុជាបានចារចំណារអនុស្សាវរីយ៍លើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានខ្លឹមសារដូចតទៅ៖*

**"ថ្ងៃនេះក្រុមការងារមកពីស្ថានទូតស៊ុយអែតរបស់យើងបានសិក្សាយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រសម័យងងឹតរបស់ប្រទេសកម្ពុជា ព្រមទាំងកិច្ចខិតខំប្រឹងប្រែងក្នុងការរារាំងមិនឱ្យអំពើឃោរឃៅនិងអំពើហិង្សារំលោភសិទ្ធិមនុស្សកើតមានសារជាថ្មី។ សូមអបអរសាទរចំពោះការងារដ៏មានសារសំខាន់ និងកិច្ចខិតខំប្រឹងប្រែងបន្តទៀត"។**

# ការថែរក្សាសន្តិភាពនិងការអភិវឌ្ឍនៅស្រុកអន្លង់វែង

## អនាគតរបស់ប្រទេសកម្ពុជា ពឹងផ្អែកទៅលើជោគជ័យក្នុងការយកឈ្នះលើអតីតកាលរបស់ខ្លួន

ឆាំង យុ





សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អនាគតនៃប្រទេសកម្ពុជា ពឹងផ្អែកទៅលើប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះនិងរើសអើង ដែលភាគច្រើនបានទទួលរងទុក្ខវេទនានៅក្រោមរបបខ្មែរក្រហម។ ក្នុងស្មារតីជួយដល់សហគមន៍ក្រីក្រ ងាយរងគ្រោះនិងរើសអើងនានាក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងដាក់ដំណើរការសាកល្បងនូវកម្មវិធីអភិវឌ្ឍរបស់ខ្លួននៅក្នុងស្រុកអន្លង់វែង។

ស្ថិតនៅជើងភ្នំដងរែកនាតំបន់ដាច់ស្រយាលមួយឯភាគខាងជើងប្រទេស មានព្រំប្រទល់ជាប់ទៅនឹងប្រទេសថៃ ស្រុកអន្លង់វែងមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយនឹងអតីតកាលដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជា។ ក្រោមការគ្រប់គ្រងរយៈពេលខ្លី ប៉ុន្តែសាហាវយោរយៅដែលត្រូវបានស្គាល់តាមរយៈ «វាលពិឃាត» និងការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាប្រមាណពីរលាននាក់ របបប្រល័យពូជសាសន៍ខ្មែរក្រហមត្រូវបានផ្តួលរំលំដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពវៀតណាម។ ជួរភ្នំនិងព្រៃព្រឹក្សាក្នុងស្រុកអន្លង់វែង គឺជាទីតាំងដែល ប៉ុល ពត និងក្រុមខ្មែរក្រហម បានភៀសខ្លួនទៅកាន់កាប់ ហើយចាប់តាំងពីពេលនោះមក តំបន់នេះបានក្លាយជាសមរភូមិសង្គ្រាមទ័ពព្រៃជាបន្តបន្ទាប់អស់រយៈកាលជាង២០ឆ្នាំ។ នៅចុងបញ្ចប់ ក្នុងខែធ្នូ ឆ្នាំ១៩៩៨ កងទ័ពខ្មែរក្រហមដែលនៅសេសសល់ចុងក្រោយបង្អស់ បានយល់ព្រមទម្លាក់អាវុធ និងវិលមករួមរស់នៅក្នុងសង្គមកម្ពុជាវិញ។ ទោះជាយ៉ាងណាក្តី សន្តិភាពនាំឡូងរយៈពេលម្ភៃឆ្នាំចុងក្រោយនេះ មិនបានលុបបំបាត់នូវប្រវត្តិសាស្ត្រនៃទីកន្លែងដ៏អាស្រូវ ឬទីតាំងជាក់ស្តែងនៃអំពើហិង្សាប្រឆាំងបក្ខពួក ពលកម្មដោយបង្ខំ ការសម្លាប់យ៉ាងឃោរឃៅ ព្រមទាំងទីតាំងឃុំឃាំង ទីតាំងបូជា និងផ្នូររបស់ ប៉ុល ពត ជាដើមនោះទេ។

ប្រមាណ ៨០ភាគរយ នៃប្រជាជនស្រុកអន្លង់វែងសព្វថ្ងៃ គឺជាអតីតខ្មែរក្រហម ភាគច្រើនប្រកបមុខរបរកសិកម្មដុតព្រៃ ដែលមួយចំនួនបានបណ្តាលឲ្យមានការបំផ្លិចបំផ្លាញព្រៃឈើឥតគណនានៅក្នុងប្រទេស។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមដំណើរការនៃការផ្សះផ្សា ការចូលរួមចំណែក និងការអប់រំ តាមរយៈការកែប្រែផ្ទះមួយនៅលើភ្នំដងរែក ដែលធ្លាប់បានប្រើប្រាស់ដោយ ប៉ុល ពត និងថ្នាក់ដឹកនាំខ្មែរក្រហម ដើម្បីរៀបចំផែនការសកម្មភាពហិង្សាឲ្យទៅជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដឹកនាំដោយបណ្ឌិត លី សុខឃាង។

ក្រសួងទេសចរណ៍ និងក្រុមការងារស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានកំណត់ទីតាំងប្រវត្តិសាស្ត្រយ៉ាងហោច ១៤កន្លែង គិតចាប់ពីស្រុកអន្លង់មកដល់កំពូលភ្នំដងរែក។ ដោយសហការជាមួយសហគមន៍ក្នុងតំបន់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងតភ្ជាប់ទីតាំងប្រវត្តិសាស្ត្រដែលបានកំណត់ទាំងអស់នេះ បង្កើតជាផ្លូវថ្មើរជើងបត់បែនឆ្លងកាត់ទីក្រុង និងតំបន់កសិកម្មផ្សេងៗ។ ដំណើរការនៃការសិក្សាយល់ដឹងអំពីប្រវត្តិសាស្ត្រ និងដំណើរនៃការធ្វើឲ្យជាសះស្បើយ ដោយប្រើប្រាស់ទេសភាព បានច្របាច់បញ្ចូលគ្នាតែមួយ បង្កើតជាបទពិសោធន៍ថ្មើរជើងដ៏មានឥទ្ធិពល និងសមស្របតាមបុគ្គលម្នាក់ៗ។ ដំណើរដោយថ្មើរជើងនឹងបញ្ចប់នៅព្រឹកនៃថ្ងៃទីបី ដោយការគន់មើលថ្ងៃរះនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងស្ថិតនៅលើច្រាក់ភ្នំដងរែក។

ប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាអ្វីដែលធ្វើឲ្យស្រុកអន្លង់វែងគួរជាទីចាប់អារម្មណ៍ប្លែកពីគេ ក៏ប៉ុន្តែតំបន់នេះមិនមែនមានសារសំខាន់ដោយសារតែប្រវត្តិសាស្ត្រក្នុងតំបន់តែមួយមុខប៉ុណ្ណោះទេ។ ស្រុកអន្លង់វែងមានតំបន់ប្រវត្តិសាស្ត្រយោធាជាច្រើន ដែលជាអតីតមូលដ្ឋានរបស់កងកម្លាំងយោធាកម្ពុជា និងរឿងរ៉ាវពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធរវាងកងកម្លាំងយោធា, ការប្រឈមតទល់គ្នា និងការធ្វើសមយុទ្ធក្នុងតំបន់ជាច្រើន។ ប្រវត្តិសាស្ត្រយោធាដូចទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហមដែរ គឺមិនត្រឹមតែផ្តល់នូវការយល់ដឹងជាក់ច្បាស់អំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញអំពីការតស៊ូនិងភាពមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជាទៀតផង។ វិធីសាស្ត្ររបស់យើងក្នុងការអភិវឌ្ឍតំបន់ គឺមិនមែនលុបបំបាត់ការចងចាំពីអំពើហិង្សា និងរបួសផ្លូវចិត្តនោះទេ ក៏ប៉ុន្តែគឺកែប្រែតំបន់នេះ ពីទីតាំងនៃការឈឺចាប់ទៅជាទីតាំងនៃការរីកចម្រើនទៅថ្ងៃមុខ។ ជាឧទាហរណ៍ នៅទីតាំងមួយនៃការប្រព្រឹត្តអំពើហិង្សាលើស្ត្រី គឺទីតាំងដែលភរិយានិងកូនរបស់អតីតមេដឹកនាំផ្តាច់ខ្លួនម្នាក់ ត្រូវបានរំលោភនិងសម្លាប់ អាចកែប្រែទៅជាមជ្ឈមណ្ឌលសម្រាប់ស្ត្រីដោយផ្តល់ជាការបណ្តុះបណ្តាលនិងការពិគ្រោះយោបល់។ ឃ្លាំងផ្ទុកនិងកែច្នៃគ្រាប់មីនអាចកែលម្អជាទីតាំងផលិតឈើប្រិត រទេះជនពិការ និងកង់។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានបំណងផ្លាស់ប្តូរមុខមាត់វិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងប្រទេសមួយដែលប្រជាជនភាគច្រើនរកចំណូលបានតិចជាង៦ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ ប្រទេសនេះគួរ



*សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងអំឡុងពេលទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០។*
*(ប្រភពរូបថត៖ ទំព័រហ្វេសប៊ុក សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា)*

បង្កើនសកម្មភាពទេសចរណ៍ឲ្យបានច្រើន ដែលប្រសិនបើមិនអាចជាសកម្មភាពលក្ខណៈអប់រំ យ៉ាងហោចណាស់សកម្មភាពទេសចរណ៍ទាំងនោះគួរតែគាំទ្រផ្ទាល់ចំពោះប្រជាជនក្រីក្រ។ មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងរៀបចំកម្មវិធីសាកល្បងដែលផ្តល់ការគាំទ្រផ្ទាល់ចំពោះប្រជាជនកម្ពុជាក្នុងតំបន់ តាមរយៈការបង្រៀនភាសាអង់គ្លេស និងប្រសិនបើអាចជាភាសាបារាំងនិងភាសាចិន ដោយដោះដូរជាមួយនឹងទីតាំងស្នាក់អាស្រ័យដើម្បីសិក្សាយល់ដឹងអំពីជីវភាពនៅតាមទីជនបទ ប្រវត្តិសាស្ត្រ និងវប្បធម៌។ វិស័យទេសចរណ៍ អាចផ្តល់ជាអត្ថប្រយោជន៍រួមតាមរយៈការគាំទ្រចំពោះប្រជាជនក្រីក្រ ឬប្រជាជនងាយរងគ្រោះនិងរើសអើង ព្រមទាំងភាពសប្បាយរីករាយនិងភាពសុខដុមរមនាសម្រាប់ទេសចរ។ ទេសចរដែលចូលរួមក្នុងសកម្មភាពទេសចរណ៍ខាងលើអាចទទួលបាននូវការបញ្ជាក់ថា ខ្លួនបានចូលរួមចំណែកតបស្នងដល់សហគមន៍ក្នុងតំបន់ ស្របពេលដែលកំពុងទទួលបានបទពិសោធន៍ដ៏ស្រងព្រេងឬអារម្មណ៍ជ្រះថ្លា ចាកចេញពីពិភពលោកដ៏មមាញឹករបស់យើងសព្វថ្ងៃនេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានបំណងដាក់បញ្ចូលសកម្មភាពកីឡានៅធ្លាខាងក្រៅ ចូលទៅក្នុងវិស័យទេសចរណ៍កម្ពុជា។ ដំណើរថ្មើរជើង ការដើរភ្នំ និងសកម្មភាពកីឡានៅធ្លាខាងក្រៅផ្សេងៗ អាចជាផ្នែកមួយយ៉ាងសំខាន់ ដែលមិនត្រឹមកែលម្អទស្សនៈយល់ឃើញរបស់បរទេសមកលើប្រទេសកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែប្រែលើការដែលយុវជនកម្ពុជាមានភាពរីករាយចំពោះប្រទេសខ្លួន និងផ្តល់ឱកាសដល់ប្រជាជនក្នុងតំបន់បង្ហាញអំពីសហគមន៍ វប្បធម៌ និងរឿងរ៉ាវជីវិតរបស់ខ្លួនទៀតផង។ មជ្ឈមណ្ឌលឯកសារកម្ពុជា ចង់អភិវឌ្ឍតំបន់អន្លង់វែងទៅជាទីតាំងមួយ ដែលព្រឹត្តិការណ៍កីឡានៅធ្លាខាងក្រៅនានាអាចប្រារព្ធឡើងបានដោយសុវត្ថិភាព និងមានរបៀបរៀបរយ។ កីឡារត់ចម្ងាយ ការដើរភ្នំ និងព្រឹត្តិការណ៍កីឡាផ្សេងៗទៀត អាចជាវិធីសាស្ត្រដែលរួមបញ្ចូលការថែទាំសុខភាពផ្លូវកាយទៅក្នុងវិស័យទេសចរណ៍ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ទេសចរអាចទទួលយកបទពិសោធន៍បែបផ្សងព្រេង ប៉ុន្តែប្រកបដោយសុវត្ថិភាព តាមរយៈព្រឹត្តិការណ៍កីឡានៅធ្លា

ខាងក្រៅ ដែលអ្នកទាំងនោះនឹងទទួលបានចំណេះដឹងវប្បធម៌ប្លែកពីគេរបស់ប្រជាជនក្នុងតំបន់ អមជាមួយនឹងការប្រោកដចិត្តថាកិច្ចចូលរួមរបស់ខ្លួន នឹងជួយលើកស្ទួយសេដ្ឋកិច្ចក្នុងសហគមន៍និងក្នុងតំបន់ ព្រមទាំងផ្តល់តម្លៃដល់ប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ និងរើសអើង។

អនាគតនៃប្រទេសកម្ពុជា ពឹងផ្អែកខ្លាំងទៅលើការច្នៃបង្កើតថ្មីនិងការវិនិយោគលើគំនិតនិងបច្ចេកវិទ្យាថ្មីៗ ក៏ដូចជាការវិនិយោគលើប្រជាជនរបស់ខ្លួនដែរ។ ដើម្បីឲ្យមានការអភិវឌ្ឍជាងនេះ រួមទាំងការចូលរួមយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ចពិភពលោក ប្រទេសកម្ពុជាត្រូវតែធ្វើការវិនិយោគឲ្យមានសមតុល្យចំពោះប្រជាជននិងបច្ចេកវិទ្យា ដោយមិនលះបង់ផ្នែកណាមួយឡើយ។ ដើម្បីសម្រេចបានសមិទ្ធផលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងដាក់បញ្ចូលការអប់រំផ្នែកបច្ចេកវិទ្យាព័ត៌មានជាសមាសធាតុមួយ ក្នុងចំណោមសមាសធាតុជាច្រើនទៀតនៃកិច្ចការអភិវឌ្ឍរបស់ខ្លួននៅក្នុងស្រុកអន្លង់វែង។ យុវជនកម្ពុជាអាចទទួលបានកុំព្យូទ័រនិងបរិក្ខារព័ត៌មានវិទ្យាទំនើបនិងទាន់សម័យបំផុត ប៉ុន្តែប្រសិនបើមនុស្សជំនាន់ថ្មីទាំងនោះគ្មានជំនាញ ចំណេះដឹង និងសមត្ថភាពមូលដ្ឋាន ដើម្បីប្រើប្រាស់បរិក្ខាខាងលើនិងសិក្សាអំពីឧបករណ៍ដែលទំនើបជាងនេះទេ មិនថាការវិនិយោគទៅលើគំនិតឬបច្ចេកវិទ្យាថ្មីច្រើនយ៉ាងណាទេ គឺសុទ្ធសឹងតែឥតន័យខ្លឹមសារ។

២៥ភាគរយនៃប្រជាជនក្នុងស្រុកអន្លង់វែង ទទួលរងពិការភាពរាងកាយដោយសារតែគ្រាប់មីននិងសង្គ្រាមទ័ពព្រៃដ៏វែងអន្លាយ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ខិតខំបង្កើតឲ្យមានការចូលរួមពីសំណាក់ជនពិការ ជាផ្នែកដ៏សំខាន់មួយនៅក្នុងកម្មវិធីសាកល្បងរបស់ខ្លួន។ តាមរយៈដំណើរការកែប្រែនេះ «ទីតាំងមួយ» ដែលធ្លាប់បង្កជារបួសស្នាមលើប្រជាជន អាចប្រែក្លាយទៅជាទីកន្លែងមួយដែលផ្តល់ជាការងារដល់ប្រជាជន តាមរយៈការបង្កើនការចល័តទីនិងការបង្កើតជាសង្គមមួយដ៏ពេញលេញ។ ភាពមិនងាយទ្រុឌទ្រោមនិងជោគជ័យនៃប្រទេសក្រោយជម្លោះមួយ គឺអាស្រ័យទៅលើការដែលប្រទេសនេះប្រឈមតទល់ជាមួយនឹងអតីតកាលនិងបច្ចុប្បន្នកាលរបស់ខ្លួន ហើយគ្មានជោគជ័យនាអតីតកាលក្នុងទំហំណាមួយ អាចធ្វើឲ្យប្រទេសមួយត្រៀមខ្លួនរួចរាល់ដើម្បីតតាំងនឹងឧបសគ្គនៅថ្ងៃអនាគតបាននោះទេ។ របបប្រល័យពូជសាសន៍ខ្មែរក្រហមបានដួលរលំអស់រយៈកាលប្រមាណ៤០ឆ្នាំមកហើយ ប៉ុន្តែប្រវត្តិសាស្ត្រនៃរបបនេះនៅតែបន្តលាន់រំពងនៅក្នុងស្ថានភាពបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ហើយនៅតែបន្តជាមេរៀនមួយសម្រាប់មនុស្សគ្រប់រូប គឺទាំងប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ។

ខ្ញុំជឿជាក់ថា អនាគតនៃប្រទេសកម្ពុជាពឹងផ្អែកទៅលើការដែលប្រទេសនេះគាំពារប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះនិងរើសអើងរបស់ខ្លួន ដែលភាគច្រើនបានទទួលរងទុក្ខក្រោមរបបខ្មែរក្រហម ពីព្រោះថាបច្ចុប្បន្នភាពនិងអនាគតកាលនៃប្រទេសកម្ពុជា គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្លាំងនៃប្រជាជនកម្ពុជា។ ដើម្បីឲ្យមានការអភិវឌ្ឍជាងនេះ រួមទាំងការចូលរួមយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ចពិភពលោក ប្រទេសកម្ពុជា ត្រូវតែធ្វើការវិនិយោគឲ្យមានសមតុល្យចំពោះប្រជាជននិងបច្ចេកវិទ្យា ដោយមិនលះបង់ផ្នែកណាមួយឡើយ។ ខ្ញុំនឹងសាកល្បងអនុវត្តកម្មវិធីដ៏មោះមុតនេះ នៅស្រុកអន្លង់វែងក្នុងឆ្នាំ២០២១ខាងមុខ។



ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសក្រសួងការពារជាតិ និងជាប្រធានក្រុមការងារសាងសង់វិមានឈ្នះ ឈ្នះ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ណាំ សា ៖ អតីតសាស្រ្តាចារ្យ

## មហាវិទ្យាល័យគរុកោសល្យ ផ្នែកគីមីវិទ្យា និង រូបវិទ្យា

*ដារ៉ាវឌ្ឍ រមេក្ខា*



*ភ្នំព្រះនេត្រព្រះ ស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ណាំ សា ភេទប្រុសអាយុ៣១ឆ្នាំ នៅឆ្នាំ ១៩៧៧។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិក្រាំងតាគា ឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ប្រវត្តិនៃការសិក្សា និងសកម្មភាពមុនឆ្នាំ១៩៧៥ ខ្ញុំស្រឡាញ់និងចូលចិត្តការសិក្សាខ្លាំងណាស់។ នៅក្នុងអំឡុងឆ្នាំ១៩៥៥ និងឆ្នាំ១៩៥៩ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាក្រាំងស្លាដែលមានទីតាំងស្ថិតនៅឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ក្រោយមកនៅក្នុងឆ្នាំ១៩៦០ ពេលរៀនដល់ថ្នាក់ទី៧ ខ្ញុំបានផ្លាស់ទៅរៀននៅសាលាបឋមសិក្សាធម្មវិន័យ។ ខ្ញុំបានប្តូរសាលារៀនញឹកញាប់ គឺនៅរវាងពីឆ្នាំ១៩៦១ ដល់ ឆ្នាំ១៩៦៣ ខ្ញុំបានរៀននៅអនុវិទ្យាល័យសោមា។ នៅពេលនោះខ្ញុំបានស្គាល់គ្រូបង្រៀនជាច្រើននាក់ហើយ ខ្ញុំបានរាប់អាន និងជិតស្និទ្ធជាមួយលោកគ្រូ ថាច់ នុយ, ប៉ែន សារី, ឃី ហាក់, វង់ ឃិញ,សៀប គង់, អោក ប្រាយ, មិន ស្រេង និងលោកគ្រូ ម៉ក ឡេង។ នៅក្នុងឆ្នាំ១៩៦៤ ខ្ញុំបានផ្លាស់មករៀននៅសាលាសង្គមរាស្រ្តនិយមទី២។ នៅទីនោះ ខ្ញុំបានចូលជា សេ.អ៊ុ.អា តាមរយៈលោក ឆ្ង

ប៉ែនហុង អតីតចាងហ្វាងវិទ្យាល័យសង្គមរាស្ត្រនិយម ទី២។ សកម្មភាពខ្ញុំជា សេ.អ៊ិ.អា នៅពេលនោះ គឺតាមដានសកម្មភាពរបស់ក្រុមខ្មែរក្រហម។ បន្ទាប់ពីខ្ញុំបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងវិញ្ញាប័នបត្រមធ្យមសិក្សាភាគទី១ នៅរាជធានីភ្នំពេញ នៅក្នុងឆ្នាំ ១៩៦៦ ខ្ញុំបានមករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ។ ខ្ញុំក៏បានដាច់ខ្សែរយៈជាមួយលោក ឆូ ប៉ែនហុង បន្ទាប់ពីគាត់ផ្លាស់ទៅកន្លែងផ្សេង។ រយៈពេលមួយឆ្នាំនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ខ្ញុំបានទាក់ទងជាមួយឈ្មោះ សេង លាងហេង, ខៀវ កុម៉ា និង នុត ប៊ុនសុង គឺជាសាស្ត្រាចារ្យនៅទីនោះ។ នៅក្នុងឆ្នាំ១៩៦៧ ខ្ញុំបានប្រឡងជាប់សញ្ញាបត្រវិញ្ញាប័នបត្រសិក្សាភាគទី២។ ក្រោយមកនៅក្នុងឆ្នាំ១៩៦៩ ខ្ញុំបានប្រឡងជាប់នៅសាលាគរុកោសល្យភ្នំពេញ។

នៅក្នុងឆ្នាំ១៩៧១ ខ្ញុំបានប្រឡងចូលរៀនផ្នែកវិទ្យាមេកានិច អគ្គិសនី និង អុបទិច ដោយបានប្រឡងជាប់នៅសាលាគរុកោសល្យជាន់ខ្ពស់។ នៅក្នុងឆ្នាំ ១៩៧២ និង ឆ្នាំ១៩៧៣ ខ្ញុំបានប្រឡងជាប់វិញ្ញាប័នបត្រផ្នែកគីមីរ៉ែ និងគីមីទូទៅ។ ក្រោយមកនៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានធ្វើជាសាស្ត្រាចារ្យបង្រៀននៅសាលា១៨ មីនា រាជធានីភ្នំពេញ។ មិនយូរប៉ុន្មាននៅក្នុងឆ្នាំ១៩៧៤ និង ឆ្នាំ ១៩៧៥ ខ្ញុំបានបង្រៀននៅមហាវិទ្យាល័យគរុកោសល្យផ្នែករូបវិទ្យា និងគីមីវិទ្យា។

## ក្រោយជម្លៀសនៅក្នុងឆ្នាំ១៩៧៥

ខ្ញុំតែងតែស៊ើបរកខ្សែរយៈរបស់ខ្ញុំ និងទាក់ទង ឈន ស្រួល អតីតវិស្វករ។ ក្រោយពីបានភ្ជាប់ខ្សែរយៈជាមួយ ឈន ស្រួល គាត់បានប្រាប់ខ្ញុំអំពីខ្សែរយៈបន្ថែមទៀតរួមមាន ៖ ចាន់ ទិត អតីតសាស្ត្រាចារ្យនៅកំពង់ស្ពឺ, មិន ហាក់គ្រុយ អតីតវិស្វករផ្នែកចំណីអាហារ, ខ្លែន អតីតនិស្សិតសាលា ១៨ មីនា, ធុល អតីតនិស្សិតច្បាប់, ផន គិញ នៅភ្នំពេញ, សុខ សាថា វិស្វករ, សុខ ទីណូ អ្នកបើកយន្តហោះ និង ហួយ កែក្រាវី អតីតសាស្ត្រាចារ្យ។ ក្រោយពីបានស្គាល់ខ្សែ ឈន ស្រួល បានដាក់ផែនការឲ្យខ្ញុំ គឺត្រូវខិតខំស្រាវជ្រាវរកខ្សែចាស់, ឃោសនាប្រជាជនឲ្យប្រឆាំងបដិវត្តន៍, បំផ្លាញសម្ភារកសិកម្ម និងបំផ្លាញផលដំណាំប្រជាជន។ ខ្ញុំបានឃោសនាប្រជាជនឲ្យប្រឆាំងបដិវត្តន៍ និងលើកពីបដិវត្តន៍មានភាពតឹងតែងព្រមទាំងបានបំផុសប្រជាជនឲ្យរំលាយភ្លឺធ្វើឲ្យទឹកហូរចេញពីស្រែ និងបានបំផ្លាញនង្គ័លអស់ចំនួន៣ ។

នៅក្នុងខែសីហា ឆ្នាំ១៩៧៥ ខ្សែរបស់ខ្ញុំ៨នាក់ខាងលើ និង ឈន ស្រួល ត្រូវអង្គការជម្លៀសទៅកាន់ស្រុកភ្នំស្រុក តំបន់៥ ភូមិភាគពាយ័ព្យ។ ចំណែកខ្ញុំ នៅខែធ្នូ ឆ្នាំ ១៩៧៥ ត្រូវបានជម្លៀសចេញពីតំបន់ ៣៣ ឲ្យទៅរស់នៅភូមិរោលជ្រូក ឃុំទានកាំ (បច្ចុប្បន្នស្ថិតនៅក្នុងឃុំជប់វារី) ស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ។

នៅក្នុងឆ្នាំ១៩៧៦ អង្គការចាត់តាំងឲ្យខ្ញុំបញ្ជូនស្រូវនៅគោកល់ន់ ដែលពេលនោះខ្ញុំបានជួបជាមួយ គូ ហូ អតីតសាស្ត្រាចារ្យគឺជាខ្សែចាស់របស់ខ្ញុំ។ ហូ គូ បានប្រាប់ខ្ញុំថាគាត់ទទួលផែនការពីឈ្មោះ ជិន តៃហេង ហើយគាត់បានបំផុសប្រជាជនឲ្យស្អប់បដិវត្តន៍នៅពេលជម្លៀសមកតាមផ្លូវ ដោយបាននិយាយថាបដិវត្តន៍ធ្វើបាបប្រជាជន មិនឲ្យប្រជាជនហូបគ្រប់គ្រាន់ និងមិនឲ្យប្រជាជនមានសេរីភាព។

នៅខែឧសភា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំឲ្យទៅចម្ការកប្បាសសហករណ៍គិរីវ័នតំបន់ ៥ ។ ពេលនោះខ្ញុំបានស្គាល់ ជិត តៃហេង ដែល គូហូ ប្រាប់ខ្ញុំតាំងពីខែមុន។ ខ្ញុំបានស្គាល់ ជិត តៃហេង និងរស់នៅជាមួយគ្នាយ៉ាងស្និទ្ធស្នាល ហើយយើងបានធ្វើសកម្មភាពធ្វើឲ្យខូចខាតកប្បាសអស់ចំនួន ២ ហិកតា ដោយយកថ្នាំទៅបាញ់ធ្វើឲ្យកប្បាសទាំងនោះរលួយគល់។ យើងបានបំផុសឲ្យ



អូររន្ទះបាញ់ខាងត្បូង ស្ថិតឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



*វត្តព្រះនេត្រព្រះ ថតពីលើអាកាស។ វត្តព្រះនេត្រព្រះ ស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ប្រជាជនប្រឆាំងមាគ៌ាកសាងប្រទេស មិនឲ្យប្រជាជនធ្វើការនៅក្នុងចម្ការ និងលួចអង្ករនៅក្នុងចម្ការកប្បាសចំនួនបីបាវយកទៅដូរថ្នាំពេទ្យ ដើម្បីត្រៀមទុកពេលរត់ទៅសៀម។ រយៈពេលបួនខែក្រោយមក អង្គការបានផ្លាស់ខ្ញុំមកនៅកន្លែងបិតទំនប់ទឹកទួលប្រាសាទ ស្ថិតនៅស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ។ មុនពេលខ្ញុំទៅ គន បានប្រាប់ខ្ញុំឲ្យទាក់ទងឲ្យជាប់ជាមួយខ្មែរដែលនៅក្នុងតំបន់ទួលប្រាសាទ គឺមានឈ្មោះ ទីន អតីតទាហាន, ប៉ូ អតីតទាហាន, ហាក់ អតីតកុម្មង់ដូ បច្ចុប្បន្នគឺជាប្រជាជនថ្មីនៅភូមិប្រាសាទ។ បន្ទាប់ពីខ្ញុំបានទៅដល់ទីនោះ និងទាក់ទងអ្នកទាំងបីនាក់រួច យើងបានធ្វើសកម្មភាពបំផ្លាញស្រូវទុំក្នុងស្រែអស់ ៦០ហិកតា គឺទប់ទឹកទុកឲ្យស្រូវរលួយ និងពុះបាតទូកបំផ្លាញអស់ចំនួនពីរគ្រឿង។ នៅខែតុលា ឆ្នាំ១៩៧៦ ដដែល គន ដកខ្ញុំមកនៅទំនប់ដំបូកបីវិញ។ នៅទីនោះខ្ញុំបានធ្វើសកម្មភាពបំផ្លាញស្រូវទុំខូចអស់១០០ហិកតា។ នៅចុងឆ្នាំ ១៩៧៦ ខ្ញុំបានផ្លាស់មកនៅចម្ការសណ្តែកជ្រាប់ចាស់ ហើយខ្ញុំក៏បានទំនាក់ទំនងជាមួយខ្មែរចាស់ដែលបានទំនាក់ទំនងគ្នាតាំងពីឆ្នាំ ១៩៧៦។ គន បានដាក់ផែនការឲ្យខ្ញុំបំផ្លាញផលសណ្តែក និងបំផ្លាញសម្ភារកសិកម្ម។ ក្រោយពីបានទទួលផែនការហើយ ខ្ញុំបានធ្វើសកម្មភាពបំផុសប្រជាជនមិនឲ្យកាប់ដីដាំសណ្តែក និងបំផ្លាញដំឡូងឈើអស់ចំនួនបីហិកតា ដោយយកការំបិតត្រួសចោល។

នៅខែមករា ឆ្នាំ១៩៧៧ ខ្ញុំបានទទួលផែនការពី គន ដើម្បីរៀបចំធ្វើរដ្ឋប្រហារផ្តួលរំលំបដិវត្តន៍ ដោយទាក់ទងសៀមដើម្បីសុំអាវុធ និងប្រមូលកម្លាំង សេ.អ៊ី.អា។ ក្រោយមក គន បាននាំខ្ញុំទៅជួប ជិន តៃហេង នៅស្វាយស៊ីសុផុន។ បន្ទាប់មកទៀត ជិត តៃហេង បាននាំខ្ញុំទៅជួប ហ៊ីង្ស គណៈតំបន់៥។ ហ៊ីង្ស បានចាត់ឲ្យខ្ញុំ និង គន យកមាសដែលប្រមូលបានពីប្រជាជនថ្មី ទៅដូរយកអាវុធពីសៀម។



*ព្រះសង្ឃនៅវត្តព្រះនេត្រព្រះ កំពុងប្រើម៉ាស៊ីនដើម្បីពុះអុស។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្នុងការធ្វើដំណើរមានឡានទីសារ របស់ ហ៊ីង ជាអ្នកជូនទៅ។ មុនពេលទៅ ហ៊ីង បានប្រាប់ខ្ញុំ និង តនឲ្យទាក់ទងជាមួយ ងិន សុង និង មិន ហេង អតីតស័ក្ដិ៥បង្កប់ខ្លួននៅព្រំដែនសៀមដើម្បីចាំនាំអាវុធពីសៀមមកព្រំដែន។ ចំនួនអាវុធដែលទទួលបានមានអាវុធចំនួន៦ហឹប និងគ្រាប់បែកចំនួន៦០ឡាំង។ អាវុធទាំងអស់ដែលទទួលបានយកមកប្រគល់ឲ្យ ហ៊ីង នៅស្វាយស៊ីសុផុន ហើយខ្ញុំមិនដឹងថាគាត់យកទៅទុកនៅទីណាទេ។

នៅខែមីនា ឆ្នាំ១៩៧៧ ក្រោយពីខ្ញុំមកពីស៊ីសុផុនវិញខ្ញុំបានផ្ដាច់ទំនាក់ទំនងជាមួយ តន មូលហេតុ តនត្រូវបានផ្លាស់ទៅមន្ទីរកសិដ្ឋានរដ្ឋព្រៃមាន់។ តាមការប្រាប់របស់ តន បានឲ្យខ្ញុំរក្សាទំនាក់ទំនងជាមួយឈ្មោះ ស និងទទួលផែនការពី ស គឺលាក់ស្បៀងទុកដើម្បីផ្គត់ផ្គង់ក្រុម សេ.អ៊ី.អា។

ក្រោយពីបានទទួលផែនការខ្ញុំនិងបក្ខពួកបានលាក់អង្ករចំនួន១០បាវ ដើម្បីទុកឲ្យឈ្មោះ ស យកទៅឲ្យក្រុមខ្មែរសេរីនៅភ្នំជ្រាប់។ ក្រោយមកនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនខ្ញុំនៅភូមិរោលជ្រូកសហករណ៍គិរីវ័ន។ អង្គការបានបញ្ជូនខ្ញុំទៅឃុំឃាំងនៅជប់បាន៣ថ្ងៃ ក្រោយមកបញ្ជូនមកបាត់ដំបង ប៉ុន្ដែមិនបានសួរចម្លើយខ្ញុំច្រើនទេ។ រហូតដល់ថ្ងៃទី២៨ ខែសីហា អង្គការបានបញ្ជូនខ្ញុំមកមន្ទីស-២១។ នៅមន្ទីរស-២១ អង្គការបានធ្វើទារុណកម្មដោយចាក់ទឹក ហើយខ្ញុំបានសារភាពពីខ្សែ សេ.អ៊ី.អា។

កំណត់ចំណាំ ៖ អត្ថបទនេះសង្ខេបចេញពីឯកសារចម្លើយសារភាពលេខD១៨៦៤៣។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្ដិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ណាំ សា ពិតប្រាកដយ៉ាងណានោះទេ។

# គ្រាន់តែហូបផ្លែត្របែក ធ្វើឱ្យជីវិតខ្ញុំស្ទើរស្លាប់

អ៊ុន សុជាទី



ម៉ម សុផាត សព្វថ្ងៃមានអាយុ៥៦ឆ្នាំ រស់នៅក្នុងភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ (ម៉ម សុផាត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ផ្លែត្របែក

ដើមត្របែកបានដុះស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ហើយប្រជាជនកម្ពុជាអាចបេះផ្លែវាហូបបានគ្រប់ពេល។ កន្លងផុតអស់រយៈពេលជាង៤០ឆ្នាំទៅហើយ ដែលខ្ញុំបានភ្លក់រសជាតិផ្លែត្របែក ខ្ចីពណ៌ខៀវស្រងាត់មួយផ្លែ។ត្របែកនោះមានដើមដុះនៅលើភ្លឺស្រែ តាមបណ្តោយផ្លូវដែលខ្ញុំដើរត្រឡប់មកពីវាលស្រែវិញ។ នៅពេលនោះ មានកុមារជាច្រើនបានដើរនៅតាមបណ្តោយផ្លូវយ៉ាងប្រញាប់ប្រញាល់ហាក់បីដូចជាកំពុងសំដៅទៅរកអ្វីមួយ បន្ទាប់ពីបានបំពេញការងារនៅតាមវាលស្រែពេញមួយព្រឹក។ ខ្ញុំសង្កេតឃើញគ្មាននរណាម្នាក់ចាប់អារម្មណ៍នឹងដើមត្របែកនៅតាមផ្លូវដើរនោះទេ។ ពេលខ្ញុំដើរមកដល់ដើមត្របែក មិនបង្អង់យូរខ្ញុំបានឈោងដៃទៅបេះផ្លែវា។ ចៃដន្យ មានកុមារចំនួនពីរបីនាក់បានដើរមកក្បែរ រួចនិយាយដាស់តឿនខ្ញុំថា «កុំបេះត្របែកនេះ ប្រយ័ត្នមានរឿង» ។ ខ្ញុំឮតែសំឡេងរបស់កុមារទាំងនោះនិយាយតែប៉ុណ្ណោះ ប៉ុន្តែខ្ញុំមិនបានស្តាប់ដោយយកចិត្តទុកដាក់ទេ ហើយខ្ញុំក៏មិនបានឆ្លើយតបទៅកុមារទាំងនោះដែរ។ ក្នុងចិត្តរបស់ខ្ញុំគិតថា នេះគ្រាន់តែជាផ្លែត្របែកខ្ចីមិនទាន់នឹងល្មមអាចហូបបានស្រួលផង តើហេតុអ្វីបានអាចទៅជាមានរឿងធ្ងន់ធ្ងរទៅវិញ។

រំពុកដល់ថ្ងៃនោះ តាំងពីព្រឹកព្រហាមម៉ោង ៣ ទៀបភ្លឺ មេកងស្រែកដាស់កុមារទាំងអស់នៅក្នុងកងឲ្យក្រោកទៅធ្វើការ។ ម្នាក់ៗស្ទុះស្ទាវួសរវាន់ និងគ្មានបង្អែបង្អង់ឡើយ។ ខ្ញុំទាញបានដងវែក និងសង្រែកដែលមានរៀបកណ្តាប់សំណាប ដែលខ្ញុំបានរៀបចំត្រៀមទុកតាំងពីយប់រួចជាស្រេចនោះ រែកសំដៅទៅស្រែយ៉ាងលឿនៗ នៅលើស្មាខ្ញុំម្ខាងៗមានកណ្តាប់សំណាបចំនួន ២ ដប ដែលស្មើនឹង ៨ កណ្តាប់។ ខ្ញុំដើរដងរត់ដងឲ្យទាន់មេកង និងកុមារដទៃទៀតៗ ខ្ញុំត្រូវរែកកណ្តាប់ក្នុងចម្ងាយផ្លូវជាច្រើនគីឡូម៉ែត្រ។ ខ្ញុំត្រូវដើរនៅលើភ្លឺស្រែរដាក់រដុប និងកាត់ផ្លូវមេយងងឹតសូន្យឈឹង។ នៅពេលដែលខ្ញុំធ្វើដំណើរទៅដល់វាលស្រែ ព្រះអាទិត្យបានចាប់ផ្តើមបោលស្រមោលពន្លឺព្រឹមៗ។ គ្មាននរណាម្នាក់បានឈប់សម្រាកឡើយ បន្ទាប់ពីយើងដើរយ៉ាងឆ្ងាយ។ ទៅដល់ស្រែភ្លាម ម្នាក់ៗស្ទុះទាញយកកណ្តាប់សំណាបរបស់ខ្លួនដើរចុះទៅក្នុង

ស្រែដែលកងភ្ជួរទើបបានភ្ជួររួចថ្មីៗ។ ខ្ញុំបានរាយកណ្តាប់សំណាបរបស់ខ្ញុំយ៉ាងរហ័ស ព្រោះមេកងកំពុងតែឈរមើលពីខាងក្រោយ។ បន្ទាប់មក យើងបាននាំគ្នាស្ទូងប្រដេញគ្នាយ៉ាងញាប់ប្រញាប់ប្រញាល់។ ម្នាក់ៗគិតតែពីឱនស្ទូងដោយមិនហ៊ានងើបមុខឡើយ ទោះបីជារោយចង្កេះ ឬចុកខ្នងយ៉ាងណាក៏ដោយ។

ពេលយើងស្ទូងបានរយៈពេលបន្តិច ព្រះអាទិត្យក៏បានរះខ្ពស់បញ្ចេញកម្តៅ និងពន្លឺចែងចាំង។ មេកងបានស្រែកប្រាប់យើងឲ្យងើបឡើងពីស្ទូង ទៅសម្រាកហូបបាយថ្ងៃត្រង់ ខណៈដែលក្រពះរបស់ខ្ញុំកូរព្រួសូរចេញមកក្រៅ ព្រោះមិនទាន់មានចំណីចូលក្នុងពោះតាំងពីម៉ោង ៣ ទៀបភ្លឺមកម្ល៉េះ។ មនុស្សម្នានាំគ្នារួសរាន់ដើរតម្រង់ទៅកន្លែងហូបបាយ ដែលមានចម្ងាយជាច្រើនគីឡូម៉ែត្រពីស្រែ។ មកដល់ត្រង់ដើមត្របែកមួយ ខ្ញុំបានបេះផ្លែវាហើយខាំទំពារដើម្បីបំពេញក្រពះដែលកំពុងទាមទារអាហារ។ ត្របែកនោះមានរសជាតិជូរលាយចត់ ព្រោះវានៅខ្ចីមិនទាន់ល្មមហូបនោះទេ។ ដោយខ្ញុំឃ្លានខ្លាំងពេក ខ្ញុំបានទំពារវាឲ្យម៉ត់ជញ្ជក់យកតែទឹកប៉ុណ្ណោះ។ វាពិតជាមានរសជាតិឆ្ងាញ់ណាស់។ រំពេចនោះ មេកងឈ្មោះ តាខេន បានមកដល់។ តាខេន គឺជាមេកងកុមារ។ គាត់បានស្រែកគំហកដាក់ឲ្យខ្ញុំ និងបានទាញយកផ្លែត្របែកពីដៃរបស់ខ្ញុំបោះចោល។ តាខេន បានជេរខ្ញុំថា អាពួកសេរីហ៊ានបេះផ្លែត្របែកស៊ី។ មេកងគិតថា ខ្ញុំគឺជាប្រជាជនថ្មីមកពីភ្នំពេញ។ បុរសម្នាក់ទៀតឈ្មោះ តាពេច គឺជាមេកងកុមារដែរ ក៏បានដើរចូលមកដល់ដែរ។ តាខេន និង តាពេច បានចាប់ខ្ញុំ និងយកវល្លិ៍មកចងដៃខ្ញុំយ៉ាងតឹង។ ដៃខ្ញុំទាំងពីរត្រូវបានទាញចូលមកប្រឡោះជន្លង់ រួចហើយចងផ្តោបជាមួយនឹងជើងទាំងសងខាង។ បន្ទាប់មក តាខេននិងតាពេច បានលើកខ្ញុំបោះចូលទៅក្នុងត្រពាំងនៅក្បែរនោះ រួចហើយក៏ដើរចេញទៅបាត់។

ពេលនោះ ខ្ញុំមិនគិតថា នឹងនៅមានជីវិតរស់ឃើញមុខបងប្អូន និងម្តាយឪពុកទៀតទេ ព្រោះដៃជើងរបស់ខ្ញុំជាប់ចំណង។ ពេលខ្ញុំលិចដល់បាតត្រពាំង ច្រមុះខ្ញុំចាប់ឈ្លក់ទឹក។ ពេលខ្ញុំខំប្រឹងដកដង្ហើម ទឹកកាន់តែហូរចូលមាត់ធ្វើឲ្យពោះរបស់ខ្ញុំធំប៉ោង។ ខ្ញុំបានខំរើបម្រះ និងធាក់ឡើងទៅលើផ្ទៃទឹកដើម្បីដកដង្ហើមជាច្រើនដង។ សំណាងល្អ មានយុវជនមួយក្រុមបានឃើញសក់ខ្ញុំ និងឮសំឡេងខ្ញុំរើបម្រះនៅក្នុងទឹកត្រពាំង។ យុវជនពីរនាក់បានចុះមកស្រង់ខ្ញុំឡើងទៅលើគោក និងជួយស្រាយចំណងចេញ ហើយក៏ដើរចេញទៅបាត់។ ខ្ញុំអស់កម្លាំងយ៉ាងខ្លាំង។ ខ្ញុំបានដើរសំដៅទៅក្នុងភូមិទៅរកម្តាយខ្ញុំ។ ខ្ញុំបានសម្ងំលាក់ខ្លួននៅក្នុងភូមិខ្លាចមេកងរកខ្ញុំឃើញទៀត នៅថ្ងៃនោះ ខ្ញុំគ្មានអាហារហូបចូលពោះទេក្រៅពីទឹកត្របែកដែលខ្ញុំជញ្ជក់ និងទឹកត្រពាំងដែលខ្ញុំផឹកពេញពោះនោះ។

## មុនរបបខ្មែរក្រហមចូលមកដល់

ភូមិស្រែជម្រៅ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ គឺជាស្រុកកំណើតរបស់ខ្ញុំ។ កាលពីតូច ខ្ញុំធ្លាប់បានចូលរៀននៅវត្តលាយបូរ ដែលស្ថិតនៅក្នុងឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ម្តាយរបស់ខ្ញុំឈ្មោះ លុយ ខន គឺជាកសិករ។ ឪពុករបស់ខ្ញុំឈ្មោះ សូ រឿង គឺជាទាហាន លន់ នល់។ ម្តាយនិងឪពុករបស់ខ្ញុំ ធ្វើស្រែចម្ការដើម្បីចិញ្ចឹមកូនៗ។ នៅក្នុងឆ្នាំ១៩៧០ ឪពុករបស់ខ្ញុំ បានចូលធ្វើជាទាហាន លន់ នល់។ គាត់បានមកស្នាក់នៅក្នុងបន្ទាយទាហានមួយនៅម៉ុំចោមចៅក្នុងរាជធានីភ្នំពេញ។ ដោយចង់រស់នៅជួបជុំក្រុមគ្រួសារ ម្តាយខ្ញុំបានយកកូនៗមករស់នៅជាមួយឪពុករបស់ខ្ញុំនៅក្នុងបន្ទាយទាហានជាមួយគ្នា។ ពេលនោះ ម្តាយរបស់ខ្ញុំនៅធ្វើការងារផ្ទះ។ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាវត្តគោកបញ្ជាន់។ ខ្ញុំចូលរៀនតាំងពីព្រឹកដល់ល្ងាចនិងត្រូវដើរដោយថ្មើរជើងចម្ងាយប្រហែល ៣ គីឡូម៉ែត្រ ពីបន្ទាយទាហានដែលខ្ញុំស្នាក់នៅ។ ដោយសារតែប្រាក់ខែទាហានរបស់ឪពុកខ្ញុំខ្វះខាត ខ្ញុំបានទៅជួយលើកបង្អែមបងស្រីម្នាក់ឈ្មោះ ម៉ៅ នៅក្នុងផ្សារថ្នល់បំបែកជារៀងរាល់ល្ងាច។ ខ្ញុំជួយលាងចាន ខ្ចប់បង្អែម និងធ្វើការងារផ្សេងៗទៀតតាមដែលគាត់ប្រើ។ បង ម៉ៅ តែងតែឲ្យលុយ និងបង្អែមមកខ្ញុំជារៀងរាល់ល្ងាចយកមកផ្ទះ។ ខ្ញុំបានរស់នៅក្នុងបន្ទាយរហូតដល់ខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥។ នៅពេលនោះខ្ញុំទើបតែមានអាយុប្រហែល ១១ ឆ្នាំតែប៉ុណ្ណោះ។ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងទីក្រុងភ្នំពេញបានហើយ មនុស្សម្នានៅក្នុងទីក្រុងទាំងអស់ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុង។ ឪពុករបស់ខ្ញុំបាននាំក្រុមគ្រួសារចាកចេញពីបន្ទាយទាហានយ៉ាងប្រញាប់ប្រញាល់។ ឪពុកមា និងសាច់ញាតិរបស់ខ្ញុំខ្លះដែលជាអតីតទាហាន លន់ នល់ ក៏ត្រូវបានខ្មែរក្រហមបាញ់សម្លាប់នៅពេលនោះដែរ។

## ត្រឡប់មកស្រុកកំណើតវិញ

មកដល់ស្រុកត្រាំកក់ដំបូងខ្ញុំ និងក្រុមគ្រួសារបានមកកាន់ភូមិមួយ។ ខ្ញុំមិនស្គាល់អ្នកណាទេ។ ប្រជាជនភាគច្រើនជម្លៀសមកពីទីកន្លែងផ្សេងៗគ្នា។ ខ្ញុំឃើញផ្ទះសម្បែងរបស់ប្រជាជននៅក្នុងភូមិត្រូវបានដុតបំផ្លាញស្ទើរគ្មានសល់ឡើយ។ វាមានសភាពខុសពីអ្វីដែលខ្ញុំធ្លាប់បានឃើញមុនពេលដែលចាកចេញទៅរស់នៅក្នុងទីក្រុងភ្នំពេញ។ មកដល់ក្នុងភូមិគ្រួសារខ្ញុំបានសាងសង់ខ្ទមតូចមួយដើម្បីស្នាក់នៅបណ្ដោះអាសន្ន។ យើងរស់នៅជាសហករណ៍ ប៉ុន្តែមិនទាន់តឹងតែងខ្លាំងនោះទេ។ រហូតដល់ខ្ញុំបានជម្លៀសមករស់នៅភូមិស្រែជម្រៅ ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំចូលកងកុមារសេរី។ កងកុមារសេរី គឺធ្វើការពិបាកជាងកងកុមារផ្សេងទៀត។ ខ្ញុំត្រូវរែកដីម្ខាង២បង្គី ។ ឪពុកម្ដាយខ្ញុំទៅធ្វើស្រែចម្ការ រីឯប្អូនៗខ្ញុំនៅតូចៗនៅផ្ទះ។

ខ្ញុំតែងតែលួចមកលេងផ្ទះជួយម្ដាយឪពុក និងបងប្អូនរបស់ខ្ញុំ។ លើកដំបូងដែលខ្ញុំបានលួចមកលេងផ្ទះ គឺប្អូនរបស់ខ្ញុំម្នាក់បានស្លាប់។ ក្រោយមក ខ្ញុំបានត្រឡប់មកលេងផ្ទះម្ដងទៀត ប្អូនខ្ញុំម្នាក់ក៏បានស្លាប់ទៀត។ នៅពេលដែលខ្ញុំបានលួចត្រឡប់មកលេងផ្ទះជាលើកទី ៣ បងរបស់ខ្ញុំក៏នៅសល់តែដង្ហើមចុងក្រោយប៉ុណ្ណោះ បន្ទាប់មកគាត់ក៏បានស្លាប់ទៅ។ បងប្អូនរបស់ខ្ញុំទាំងអស់បានស្លាប់ដោយសារតែអត់អាហារ។ សាកសពបងប្អូនរបស់ខ្ញុំបានយកទៅកប់ចោលដោយមិនបានធ្វើបុណ្យទេ។

ម្ដាយរបស់ខ្ញុំព្រួយបារម្ភពីខ្ញុំខ្លាំងណាស់។ គាត់បានសុំមេកងម្នាក់ឈ្មោះ តាសាន់ ឲ្យខ្ញុំចូលធ្វើការងារជាមួយគាត់។ តាសាន់ គឺជាមេកងក្រុមយុវជន។ គាត់មានទឹកចិត្តល្អចំពោះខ្ញុំ។ នៅក្នុងកងយុវជន ខ្ញុំមិនសូវទទួលរងការធ្វើបាបដូចនៅក្នុងកងកុមារទេ។ ខ្ញុំមានអារម្មណ៍កក់ក្ដៅព្រោះខ្ញុំលែងបានជួបមុខមេកងកុមារដែលមានបំណងចង់សម្លាប់ខ្ញុំទៀតហើយ។ ប៉ុន្តែថ្ងៃមួយ ខ្ញុំកំពុងតែប្រមូលអាចម៍គោ មេកងខេន ដែលជាមេកងកុមារសេរីដែលខ្ញុំធ្លាប់រស់នៅ បាននិយាយមកកាន់ខ្ញុំថា «អានេះអាចគេចមកដល់ទីនេះ និងនៅរស់ទៀតវើយ»។ សម្ដីប្រមាថមើលងាយនេះ បានធ្វើឲ្យខ្ញុំ ខឹងខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនតបតអ្វីឡើយ។ ខ្ញុំគិតតែពីឈ្ងោកមុខធ្វើការងារ។

នៅក្នុងកងយុវជននេះ មានកូនមេកងម្នាក់ឈ្មោះ អាកឹត បានវាយធ្វើបាប និងប្រមាថមើលងាយខ្ញុំស្ទើរតែ



ម៉ម សុផាត នៅក្នុងថ្ងៃមង្គលការកូន។
(ម៉ម សុផាត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រាល់ថ្ងៃ។ អាកឹត គឺជាកូនមេកងកសិករ។ ថ្ងៃមួយ ខ្ញុំបានដុតដំឡូងមី៣មើម ហើយ អាកឹត ក៏មកដល់។ អាកឹត បានកាយយកដំឡូងមី ដែលខ្ញុំដុតមិនទាន់នឹងឆ្អិនស្រួលផងយកទៅហូប។ ខ្ញុំសុំឲ្យអាកឹតទុកដំឡូងឲ្យខ្ញុំ ១ មើមដែរតែវាមិនព្រមឡើយ ហើយថែមទាំងជេរប្រមាថខ្ញុំ និងឪពុកម្ដាយរបស់ខ្ញុំទៀត។ ដោយទ្រាំនឹងពាក្យសម្ដីជេរទាំងអស់នោះមិនបាន ខ្ញុំក៏បានវាយ អាកឹត ជិតស្លាប់។ អ្នកនៅក្បែរៗនោះបានឃាត់ខ្ញុំឲ្យឈប់វាយ ព្រោះមិនចង់ឲ្យខ្ញុំមានទោស។ លុះស្អែកឡើង ឪពុករបស់ អាកឹត បានយកខ្សែគោបម្រុងនឹងចងខ្ញុំយកទៅសម្លាប់។ តាសាន់បានប្រាប់ខ្ញុំឲ្យគេចខ្លួន ព្រោះគាត់ដឹងថាហេតុការណ៍មិនស្រួល។

ខ្ញុំរស់នៅគេចខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ។ រហូតដល់នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចាប់ផ្ដើមវាយចូលមកក្នុងប្រទេសកម្ពុជា។ ខ្ញុំនិងគ្រួសារបានរត់ភៀសខ្លួនទៅកាន់ព្រំដែនជាមួយនឹងកងទ័ពវៀតណាម។ ប្រជាជនមួយចំនួនផ្សេងទៀត ត្រូវខ្មែរក្រហមកៀរចូលទៅក្នុងព្រៃ។ មិនយូរប៉ុន្មាន កងទ័ពវៀតណាម ក៏ដកថយចេញពីប្រទេសកម្ពុជាវិញ។ ខ្ញុំឮប្រជាជននិយាយថាថ្ងៃដែលកងទ័ពវៀតណាមដកចេញទៅនោះ គឺជាថ្ងៃចូលឆ្នាំរបស់វៀតណាម។ បន្ទាប់ពីវៀតណាមដកថយចេញពីប្រទេសកម្ពុជា ខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរអស់ជាច្រើននាក់ដែលបានរត់ទៅកាន់ព្រំដែនជាមួយកងទ័ពវៀតណាម។ ខ្មែរក្រហមបានចោទប្រជាជនទាំងអស់នោះថាមានក្បាលយួនខ្លួនខ្មែរ។ ក្រុមគ្រួសាររបស់ខ្ញុំ ត្រូវប្រឈមមុខនឹងការសម្លាប់ដែរ ប៉ុន្តែយើងរត់គេចពីកន្លែងមួយទៅកន្លែងមួយទៀត។ មួយរយៈក្រោយមក

កងទ័ពវៀតណាម បានវាយចូលមកម្តងទៀត។ ក្រុមខ្មែរក្រហមបានឃោសនាថា កងទ័ពវៀតណាមនឹងអាករសម្លាប់ប្រជាជន។ ខ្ញុំខ្លាចខ្លាំងណាស់នៅពេលនោះ។ ខ្ញុំមិនបានរត់ទៅតាមកងទ័ពវៀតណាមទៀតទេ ហើយខ្ញុំក៏សម្រេចចិត្តរត់ទៅកាន់ភ្នំដីរីរមៀល។ កងទ័ពវៀតណាមបានដេញតាមយោធាខ្មែរក្រហម។ ខ្ញុំបានជួបកងទ័ពវៀតណាមមួយក្រុម ហើយកងទ័ពវៀតណាមបានប្រាប់ខ្ញុំឲ្យត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំនិងក្រុមគ្រួសារក៏បានជួបជុំគ្នាវិញនៅក្នុងភូមិ។

## បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ

ខ្ញុំបានចាប់ផ្តើមកសាងជីវិតថ្មីជាមួយក្រុមគ្រួសារនៅក្នុងខេត្តតាកែវ។ យើងប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ អំឡុងឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៨ ខ្ញុំបានចូលរៀនបន្តមុខវិជ្ជាវេរ៉ៃ និងថាមពលនៅមហាវិទ្យាល័យតិចណូ។ បន្ទាប់ពីរៀនចប់ ខ្ញុំបានចូលបម្រើការងារនៅក្នុងមន្ទីរឧស្សាហកម្មខេត្តតាកែវ។ នៅក្នុងឆ្នាំ ១៩៨៩ និង ១៩៩០ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅបំពេញបេសកម្ម ក៥ នៅឯខេត្តប៉ៃលិនអស់រយៈពេលប្រហែល៣ខែ។ ការងារខ្ញុំគឺគ្រប់គ្រងពលករដែលទៅពីខេត្តតាកែវជាមួយនឹងមេបញ្ជាការរបស់ខ្ញុំម្នាក់ទៀតឈ្មោះ ជឹម ជឿន ដែលជាអតីតអនុប្រធានមន្ទីរឧស្សាហកម្មខេត្តតាកែវ។ នៅប៉ៃលិនប្រជាជនគឺជាជំនួយការដល់កងទ័ពដែលប្រយុទ្ធជាមួយនឹងខ្មែរក្រហម។ នៅទីនោះ យើងត្រូវជួយជីកលេណដ្ឋាន ផ្គត់ផ្គង់សម្ភារដល់កងទ័ព និងការងារផ្សេងៗទៀត។ ខ្ញុំឃើញមានការប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហមជាញឹកញយ ហើយក៏មានប្រជាជនពលីជីវិតក្នុងពេលបំពេញបេសកម្មនោះដែរ។

ខ្ញុំបានត្រឡប់មកផ្ទះវិញបន្ទាប់ពីបំពេញបេសកម្មនេះអស់រយៈពេល៣ខែ។ ខ្ញុំក៏បានរៀបការជាមួយប្រពន្ធរបស់ខ្ញុំ។ យើងមានកូនចំនួន ៤ នាក់ ស្រីចំនួន ៣ នាក់ និងប្រុសចំនួន ១ នាក់។ ដោយមើលឃើញជីវភាពគ្រួសារខ្សត់ខ្សោយពេក ខ្ញុំក៏សម្រេចចិត្តឈប់ធ្វើការរាជការត្រឡប់ទៅប្រកបមុខរបរធ្វើស្រែចម្ការវិញ។

សព្វថ្ងៃនេះ ខ្ញុំនៅផ្ទះមើលថែរក្សាចៅៗ។ កូនៗរបស់ខ្ញុំគឺជាអ្នកប្រកបរបររកស៊ីចិញ្ចឹមគ្រួសារ។

## ខ្ញុំនៅតែខ្លាចអតីតកាល

ជារឿយៗ ខ្ញុំយល់សប្តិឃើញហេតុការណ៍ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ពេលខ្លះ ខ្ញុំយល់សប្តិថា ខ្មែរក្រហមកំពុងតែដេញចាប់ខ្ញុំយកទៅសម្លាប់ និងជួនពេលខ្លះខ្ញុំយល់សប្តិថា ខ្មែរក្រហមបានស្រែកគំរាមកំហែងដាក់ខ្ញុំ។ នៅក្នុងយល់សប្តិនោះ គ្មាននរណាម្នាក់អាចជួយខ្ញុំបានឡើយ។ នៅក្នុងចិត្ត ខ្ញុំបានដឹងថាវាគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ ហើយរឿងរ៉ាវទាំងអស់នោះវាកន្លងផុតយូរណាស់ហើយ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ថាខ្លាចៗ។ ខ្ញុំមិនដឹងថានេះជាការដិតដាមអារម្មណ៍ខ្លាំងពេកនៅពេលដែលខ្ញុំបានជួបហេតុការណ៍ទាំងអស់នោះនៅក្នុងរបបខ្មែរក្រហម។

ទោះបីជាខ្ញុំឈឺចាប់យ៉ាងណា ក៏នៅមានប្រជាជនជាច្រើនទៀតរងការឈឺចាប់ដូចខ្ញុំដែរ។ ថ្ងៃមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញខ្ញុំ និង ប្រជាជនជាច្រើនទៀតឲ្យទៅទស្សនកិច្ចនៅគុកទួលស្លែង វាលពិឃាតជើងឯក និងតុលាការខ្មែរក្រហម។ ទៅដល់ទីនោះ ខ្ញុំកាន់តែយល់ដឹងច្បាស់អំពីអ្វីដែលបានកើតឡើងចំពោះប្រជាជនខ្មែរ ថាតើអ្នកជាប់ឃុំឃាំងទាំងអស់នោះបានរងទុក្ខនិងទារុណកម្មយ៉ាងធ្ងន់ធ្ងរមុននឹងស្លាប់។

ក្រោយមក ខ្ញុំបាននិយាយអំពីអ្វីដែលបានកើតឡើងនៅក្នុងគុកទួលស្លែង និងរឿងរ៉ាវរបស់ខ្ញុំប្រាប់ដល់ក្មេងៗជំនាន់ក្រោយ។ ខ្ញុំសង្ឃឹមថា ក្មេងៗជំនាន់ក្រោយនឹងរៀនសូត្រពីកំហុសនៃការដឹកនាំក្នុងរបបខ្មែរក្រហម និងចូលរួមការពារកុំឲ្យមានការកើតឡើងនៃរបបនេះម្តងទៀត។ ខ្ញុំក៏រីករាយណាស់ដែលប្រទេសកម្ពុជាអាចបង្កើតឲ្យមានតុលាការខ្មែរក្រហមសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម។ នេះជាគំរូមួយដល់សង្គមដទៃទៀតដែលជួបនឹងជម្លោះស្រដៀងគ្នានេះ។

ម៉ម សុជាត គឺជាអ្នកដាក់ពាក្យបណ្តឹងម្នាក់ទៅកាន់តុលាការខ្មែរក្រហម តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា។ សព្វថ្ងៃនេះ សុជាត មានអាយុ៥៦ឆ្នាំ រស់នៅក្នុងភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។













# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ារដ្ឋ មេត្តា

(តពីលេខមុន)

២៥៥. *នៅក្នុងពេលដំបូងនៃការងើបបះបោរ បន្ទាប់ពីការផ្តួលរំលំរបបសីហនុ នៅក្នុងឆ្នាំ១៩៧០ មក ជនជាតិចាមភាគច្រើនមានទំនាក់ទំនងល្អជាមួយខ្មែរក្រហមនៅក្នុងតំបន់«រំដោះ» ។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ មេដឹកនាំសាសនាឥស្លាមធំៗត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅក្នុងស្រុកក្រូចឆ្មារ វិហារសាសនាឥស្លាមក៏ត្រូវបានបិទ ហើយអ្នកប្រតិបត្តិសាសនាឥស្លាមត្រូវបានកៀបសង្កត់លែងឲ្យប្រតិបត្តិសាសនាឥស្លាម។ សហគមន៍ចាមមួយចំនួនត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងសហករណ៍។ ភាពតានតឹងដែលបណ្តាលមកពីបញ្ហានេះ បានកើតឡើងខ្ពស់នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៣ នៅពេលដែលកម្មាភិបាលខ្មែរក្រហម ប៉ុនប៉ងចាប់ខ្លួននិងបាញ់សម្លាប់អ្នកភូមិចាមនៅក្នុងភូមិទ្រា ដែលបណ្តាលឲ្យសហគមន៍ចាមងើបតវ៉ា និងដុតអគារមួយកន្លែង។ ខ្មែរក្រហមបានឆ្លើយតបចំពោះការបះបោរនេះ ដែលជាការងើបឡើងបះបោរមួយ ក្នុងចំណោមការបះបោរចំនួនបីលើករបស់ជនជាតិចាម នៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ដោយបានបញ្ជូនកម្លាំងទៅបង្ក្រាបការបះបោរ និងចាប់ខ្លួនអ្នកតវ៉ាទាំងនោះ។*

២៥៦. *នៅក្នុងឆ្នាំ១៩៧៤ ការចាប់ខ្លួនជនជាតិចាមបានកើតឡើង ដែលមិនត្រឹមតែការចាប់ខ្លួនមេដឹកនាំសាសនាប៉ុណ្ណោះទេ តែបានពង្រីករហូតដល់ប្រជាជនចាមទូទៅផងដែរ។*

### ៣.៤ ពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ ១៩៧៥

២៥៧. *ពុទ្ធសាសនា គឺជាសាសនាចម្បងនៅក្នុងប្រទេសកម្ពុជា យ៉ាងហោចណាស់ចាប់តាំងពីសតវត្សរ៍ទី១៣ នៅពេលដែលលទ្ធិហីនយាន ត្រូវបានផ្សព្វផ្សាយចូលមកក្នុងអាណាចក្រខ្មែរ។ ពុទ្ធសាសនា បានរីកចម្រើនរាប់សតវត្សរ៍មកហើយនឹងត្រូវបានចាត់ទុកជាសាសនារបស់រដ្ឋ នៅក្នុងឆ្នាំ១៨៤៧។*

២៥៨. *នៅពេលនោះ ពុទ្ធសាសនា បានចេញជាផ្នែកមួយនឹងអត្តសញ្ញាណជនជាតិខ្មែរ ហើយមានឥទ្ធិពលទៅលើស្ទើរតែគ្រប់ទិដ្ឋភាពនៃជីវិត ដូចភាសាខ្មែរ ប្រតិទិន អាហារ របាំ និង សិល្បៈ។ បើទោះជាគ្រហស្ថមិនបានដឹងច្បាស់អំពីភាពស្មុគស្មាញរបស់ពុទ្ធសាសនាក៏ដោយ ក៏ប៉ុន្តែវត្តមានរបស់ពុទ្ធសាសនានៅគ្រប់ទីកន្លែង បានចាក់ឫសយ៉ាងរឹងមាំ នៅក្នុងចំណេះដឹងអំពីតម្លៃនៃធម៌ និង ឱវាទសីលធម៌ និងបានលើកកម្ពស់អាកប្បកិរិយាសង្គមក្នុងចំណោមប្រជាជន។*

២៥៩. *ការបង្រៀនរបស់ព្រះពុទ្ធ (ធម៌) ត្រូវបានប្រតិបត្តិយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជាពេញមួយសតវត្សរ៍ទី២០ រហូតដល់ឆ្នាំ១៩៧៥។ ទ្រឹស្តីនៃការអំណត់អត់ធ្មត់នៅក្នុងសាសនា និងជីវិតនៅក្នុងសង្គមបានជំរុញឲ្យសង្គមមានក្តីសន្តោស មេត្តាធម៌ និង ការរួមរស់ជាមួយគ្នាដោយសន្តិភាព។ សន្តិភាពនិយម និងការ*

មិនបៀតបៀន(អហិង្សា) បង្ហាញពីសារសំខាន់នៃការប្រកាន់យកផ្លូវកណ្តាល (ខបេក្ខា) និងការស្វែងរកគុណភាព និងសុខុដុមរមនាជាមួយនឹងបរិយាកាសនៅជុំវិញខ្លួន។

**២៦០.** ព្រះសង្ឃក្នុងពុទ្ធសាសនា(ព្រះសង្ឃ) បានស្ម័គ្រចិត្តដាក់កាយទៅក្នុងពុទ្ធវិន័យតឹងតែងមួយ (ព្រះវិន័យ) ដែលទទួលយកភាពជាបព្វជិត អន្ទភាព និងប្រតិបត្តិសម្មាធិកម្មដ្ឋាន។ គុណភាពនៃសង្ឃកម្មតម្រូវបានរក្សាឲ្យស្ថិតក្នុងវង្វង់នៃការពឹងអាស្រ័យរវាងព្រះសង្ឃ និងគ្រហស្ថ ហើយសហគមន៍ត្រូវបានជំរុញឲ្យប្រគេនចង្ហាន់បច្ច័យ និងគ្រឿងបរិក្ខាថ្វាយទៅព្រះសង្ឃ ហើយព្រះសង្ឃត្រូវសូត្រធម៌ឲ្យគោរព និងឧទ្ទិសកុសលជូនបុព្វការីជនដែលបានចែកឋានទៅហើយនោះ។ លើសពីនេះទៀត ព្រះសង្ឃដើរតួនាទីសំខាន់ក្នុងការអប់រំកុមារនៅតាមវត្តអារាមទូទាំងប្រទេសកម្ពុជា ជាពិសេស នៅតាមតំបន់ជនបទ ដោយបានចូលរួមចំណែកដ៏សំខាន់ដល់ការបង្កើនអត្រាអក្ខរកម្មនៅក្នុងប្រទេស និងផ្តល់ទីកន្លែងសម្រាប់ការអប់រំមូលដ្ឋាននិងសុខមាលភាព។

**២៦១.** នៅមុនឆ្នាំ១៩៧៥ ព្រះសង្ឃមានតួនាទីរៀបចំពិធីសាសនា ប្រពៃណីផ្សេងៗ ដូចជា ការចូលរួមជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ និងសូត្រធម៌ ក្នុងពិធីបុណ្យសពជាដើម។ ព្រះសង្ឃជាមួយនឹងគ្រហស្ថសូត្រធម៌នៅតាមវត្តអារាម ដែលភាគច្រើនជាកន្លែងដែលតម្កល់សាសនាវត្ថុ និងបូជនីយវត្ថុសម្រាប់គោរពបូជា ដូចជា ព្រះពុទ្ធរូប ព្រះត្រៃបិតក សត្រា និងរូបគំនូរនានា។

ក្នុងចំណោមបុគ្គលដែលក្រោយមកបានលេចធ្លោឡើងនោះ ប៉ុល ពត, តាម៉ុក,ឌូ សាមុត និង សឺង ង៉ុកមិញ សុទ្ធតែបានទទួលការសិក្សានៅតាមវត្តអារាម ក្នុងកម្រិតផ្សេងៗគ្នា មុនពេលដែលពួកគេចូលរួមនៅក្នុងចលនាបដិវត្តន៍កម្ពុជា។

**២៦២.** ការលាចាកសិក្ខាបទដោយស្ម័គ្រចិត្តអាចធ្វើទៅបានតាមទំនៀមទម្លាប់ ហើយការអនុវត្តបែបនេះគឺស្របតាមវិន័យសាសនាដែលព្រះសង្ឃប្រតិបត្តិ។ ព្រះសង្ឃដែលមានបំណងចង់លាចាកសិក្ខាបទ ត្រូវរៀបចំពិធីដោយមានវត្តមានរបស់ព្រះសង្ឃឧបជ្ឈាដែលមាន



វត្តអារាមដែលបាក់បែកដោយសារសង្គ្រាម។

ស្នារតីល្អ ហើយព្រះសង្ឃលាចាកសិក្ខាបទនោះត្រូវបង្ហាញចេតនាច្បាស់លាស់ក្នុងការលាចាកពីភេទជាសង្ឃ។

**២៦៣.** ក្រោយពេលដែលសម្តេច នរោត្តម សីហនុ ត្រូវបានទម្លាក់ពីអំណាច នៅក្នុងឆ្នាំ១៩៧០ រណសិរ្សរួបរួមជាតិកម្ពុជាបានអះអាងថា «ព្រះពុទ្ធសាសនា នៅតែជាសាសនារបស់រដ្ឋ» នៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដែលនៅពេលនោះមានព្រះសង្ឃចំនួនប្រមាណជា៦១.០០០អង្គ ។

ចន្លោះពីឆ្នាំ១៩៧០ និងឆ្នាំ១៩៧៣ វត្តអារាមជាច្រើនត្រូវបានបំផ្លាញដោយយុទ្ធនាការទម្លាក់គ្រាប់បែកតាមផ្លូវអាកាសរបស់សហរដ្ឋអាមេរិក មកលើប្រទេសកម្ពុជា ដោយមានការប៉ាន់ប្រមាណថា វត្តចំនួនប្រមាណជា៩០០ ត្រូវបានបំផ្លាញនៅទូទាំងប្រទេស គិតត្រឹមខែមិថុនា ឆ្នាំ១៩៧៣។



(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

២៦៤. ទោះបីជាសេចក្តីប្រកាសប្តឹងឯកសាររបស់ ប.ក.ក ទាក់ទងនឹងសាសនានៅមុនឆ្នាំ ១៩៧៥ មិនសូវមានក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះមានភ័ស្តុតាងនៅចំពោះមុខដែលបង្ហាញនៅចន្លោះពីឆ្នាំ ១៩៧៣ រហូតដល់ពេលដែលរបបសាធារណរដ្ឋខ្មែរដួលរលំ ព្រះសង្ឃពុទ្ធសាសនាទទួលរងសម្ពាធផ្សេងៗ ឬត្រូវបានស្នើសុំឲ្យលាចាកសិក្ខាបទ ដើម្បីចូលរួមក្នុងចលនាបដិវត្តន៍ ដែលព្រះសង្ឃខ្លះត្រូវប្រឈមហានិភ័យនៃការសម្លាប់ បង្ខំឲ្យធ្វើពលកម្ម ជាដើម ដើម្បីផ្គត់ផ្គង់ស្បៀងអាហារទៅឲ្យកងទ័ពខ្មែរក្រហមនៅសមរភូមិ ឬត្រូវកេណ្ឌ ឬ ជ្រើសរើសឲ្យជាកងទ័ពនៅក្នុងតំបន់ដែលខ្មែរក្រហមកាន់កាប់។ ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញថានៅមុនឆ្នាំ ១៩៧៥ ព្រះសង្ឃត្រូវទទួលរងសម្ពាធ ឬ ត្រូវស្នើសុំឲ្យលាចាកសិក្ខាបទនៅក្នុងខេត្តព្រៃវែង កំពង់ឆ្នាំង កោះកុង កណ្តាល ស្វាយរៀង ស្ទឹងត្រែង កំពង់ធំ និង ខេត្តក្រចេះ។

## ៣.៥ ការរៀបចំអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា មុនឆ្នាំ១៩៧៥

២៦៥. ទោះបីជា ប្រទេសកម្ពុជាមានប្រវត្តិក្នុងការរៀបចំពិធីអាពាហ៍ពិពាហ៍ ដែលមានលក្ខណៈខុសៗគ្នានៅទូទាំងប្រទេស ទៅតាមស្ថានភាពភូមិសាស្ត្រ ទឹកដី ពេលវេលា និងសេដ្ឋកិច្ចសង្គមក៏ដោយ ក៏មានការប្រារព្ធពិធីផ្សេងៗដូចគ្នា នៅមុនឆ្នាំ ១៩៧៥ នៅក្នុងចំណោមប្រជាជនខ្មែរដែរ។

២៦៦. ការរៀបចំពិធីអាពាហ៍ពិពាហ៍ គឺជាកិច្ចការចម្បងរបស់ក្រុមគ្រួសារ និងភាគច្រើនអនាគតស្វាមីភរិយាមិនមានសិទ្ធិសម្រេចទៅលើការរៀបចំនេះឡើយ។ សហព័ន្ធអាចត្រូវផ្តួចផ្តើមឡើងដោយអនាគតស្វាមីស្នើទៅឪពុកម្តាយរបស់ខ្លួនសុំរៀបអាពាហ៍ពិពាហ៍ បន្ទាប់មកឪពុកម្តាយបុរសនោះក៏ស្វះស្វែងរកគូគ្រងដែលសក្តិសម ឬ ចូលថែវចូវឪពុកម្តាយខាងអនាគតភរិយា។ គូស្រករត្រូវបានផ្សំផ្គុំទៅតាមស្ថានភាពសង្គមគ្រួសារប្រហាក់ប្រហែលគ្នា ហើយសេចក្តីសម្រេចដំបូងអំពីការផ្សំផ្គុំនេះ ត្រូវធ្វើឡើងតាមខ្សែស្រឡាយខាងម្តាយ។

២៦៧. តាមប្រពៃណី កូនៗមិនសូវដេញដោលចំពោះការសម្រេចចិត្តរបស់ឪពុកម្តាយទៅលើបញ្ហាគូស្រករនោះទេ។ ទោះបីជាកូនស្រីត្រូវបានសាកសួរចិត្តអំពីការផ្គូផ្គងនេះ ហើយកូនស្រីអាចបដិសេធមិនរៀបការក្តីប៉ុន្តែកូនប្រុសមានសេរីភាពជាងក្នុងការជ្រើសរើសភរិយា។ ទោះបីជាយ៉ាងនេះក្តី ភាពចាំបាច់នៃការគោរពតាមឪពុកម្តាយនិងកិត្តិយសគ្រួសារតាមប្រពៃណីតម្រូវឲ្យគូស្រករដែលត្រូវបានរៀបចំត្រូវបំពេញតាមការចង់បានរបស់ឪពុកម្តាយរបស់ពួកគេ។ តាមពិតមានការរំពឹងជាទូទៅថាឪពុកម្តាយរៀបចំអាពាហ៍ពិពាហ៍ឲ្យកូនប្រុសស្រីរបស់ខ្លួនដោយផ្អែកលើការទុកចិត្តគ្នាទៅវិញទៅមក។

២៦៨. នៅពេលដែលគូស្រករបានយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍រួចហើយមានការពិភាក្សាជាមួយអាចារ្យ ដើម្បីជ្រើសរើសពេលវេលានៃការរៀបអាពាហ៍ពិពាហ៍ ដោយផ្អែកទៅលើថ្ងៃខែឆ្នាំកំណើត

(តនៅលេខក្រោយ)

# ក្រុមយុវជនសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម

**សោម ប៊ុនថន**



*ក្រុមយុវជនកាយរឹទ្ធិ យុវជនកាកបាទក្រហម និងយុវជនសហភាពសហព័ន្ធយុវជនទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារកោះថ្មៗ (ផាត សិលា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅដើមខែតុលា ឆ្នាំ២០២០ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ និងសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តត្បូងឃ្មុំ ក្រោមការផ្តួចផ្តើមរបស់ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ បានផ្ញើលិខិតមួយច្បាប់ជូនលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្នើសុំការអនុញ្ញាតឲ្យយុវជនកាយរឹទ្ធិ យុវជនកាកបាទក្រហម និងយុវជនសហភាពសហព័ន្ធយុវជនកម្ពុជាមកពីស្រុកចំនួន ៧ នៃខេត្តត្បូងឃ្មុំ ចំនួន២១០នាក់ បានចូលទស្សនាមជ្ឈ-មណ្ឌលឯកសារកោះថ្ម ក្នុងគោលបំណងចង់ពង្រីងចំណេះដឹងបន្ថែមអំពីពេលវេលាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ជាពិសេស ចាប់តាំងពីទសវត្សរ៍ឆ្នាំ៧០ រហូតដល់ទសវត្សរ៍ឆ្នាំ ៩០ ហើយនៅក្នុងដំណើរទស្សនកិច្ចនេះដែរ ក្រុមយុវជនសហភាពសហព័ន្ធយុវជនកម្ពុជានឹងឈ្វេងយល់បន្ថែមអំពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ឆ្ពោះទៅកៀងគរកម្លាំងវាយផ្តួលរបបខ្មែរក្រហម ដើម្បីរំដោះប្រទេស និងប្រជាជនឲ្យរួចផុតពីការកាប់សម្លាប់របស់ក្រុមខ្មែរក្រហមៗ តបតាមសំណើរ នេះ









លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មានសេចក្តីសោមនស្ស និងបានប្រគល់ភារកិច្ចនេះដល់លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដើម្បីសហការនិងរៀបចំទទួលស្វាគមន៍ក្រុមយុវជនទាំង ២១០នាក់ ក្រោមការដឹកនាំពីលោក ផាត សានសុខ ប្រធានការិយាល័យយុវជន នៃមន្ទីរអប់រំយុវជន និងកីឡា ខេត្ត ត្បូងឃ្មុំ។

ក្រុមយុវជនទាំង ២១០នាក់ ត្រូវបានរៀបចំជា ៧ ក្រុម ទស្សនកិច្ច ដោយក្រុម ទស្សនកិច្ចលើកទី១ ត្រូវបានរៀបចំធ្វើឡើងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០, ក្រុម ទី២ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០, ក្រុម ទី៣ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០, ក្រុម ទី៤ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០, ក្រុម ទី៥ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០, ក្រុម ទី៦ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ និង ក្រុម ទី៧ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០។ កម្មវិធីសម្រាប់ដំណើរទស្សនកិច្ចនីមួយៗ ត្រូវបានរៀបចំឡើងដូចៗគ្នាគឺ៖ ទី១) ក្រុមយុវជនចូលក្នុងបន្ទប់មជ្ឈមណ្ឌលឯកសារកោះថ្មដើម្បីទស្សនារូបថត រូបគំនូរ និងផ្ទាំងផែនទីដែលដាក់តាំងបង្ហាញអំពីពេល វេលាប្រវត្តិសាស្ត្រ។ ទី២) ក្រុម យុវជនទាំងអស់ស្តាប់ការធ្វើបទបង្ហាញរបស់ លោក ផេង ពង្សរ៉ាស៊ី ទាក់ទងនឹងព័ត៌មានពេលវេលា និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រលម្អិត ដែលបានកើតឡើងក្នុងចន្លោះឆ្នាំ១៩៧០ រហូតមកដល់ឆ្នាំ១៩៧៩។





ទី៣) និង ទី៤) ក្រុមយុវជនទាំងអស់ទស្សនាខ្សែភាពយន្តឯកសារ ផលិតដោយក្រុមការងារវិមាន ឈ្នះឈ្នះ ដែលបង្ហាញពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ចាកចេញពីបន្ទាយទាំងព្រួយបារម្ភ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ភៀសខ្លួនចូលទៅក្នុងទឹកដីប្រទេសវៀតណាម ដើម្បីកៀងគរកម្លាំងវាយផ្តួលរំលំរបបខ្មែរក្រហម និងខ្សែភាពយន្តឯកសារមួយទៀតផលិតដោយកងយោធពលខេមរៈភូមិន្ទ ដែលបង្ហាញពីមរតក ២ ធ្នូ ១៩៧៨ ជាថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីផ្តួលរំលំរបបខ្មែរក្រហម រហូតទទួលបានជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ លោក ផេង ពង្សរ៉ាស៊ី បានពន្យល់ថា ការបង្កើតរណសិរ្ស ២ ធ្នូ គឺអនុវត្តតាមគោលការណ៍គ្រឹះ ១១ខ ដែលបង្ហាញពី៖ ១) ស្មារតីរួមកម្លាំងសាមគ្គីភាព និងស្មារតីលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍ជាតិនិងប្រជាជន និង២) ការដង្រះដង្រា បង្រួបបង្រួមកសាងសន្តិភាព និងកសាងអភិវឌ្ឍន៍ប្រទេសកម្ពុជា ដោយបំបាត់ចោលនូវសង្គ្រាមនិងអំពើប្រល័យពូជសាសន៍។

បន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញរបស់លោក ផេង ពង្សរ៉ាស៊ី ក្រុមយុវជនទាំងអស់បានធ្វើដំណើរទៅមើលទីតាំងជាក់ស្តែងនៅចំណុច (x១៦) គឺជាទីកន្លែងដែលសម្តេចតេជោ ហ៊ុន សែន អុជធូបបន់ស្រន់ សូមឲ្យការធ្វើដំណើរភៀសខ្លួនរបស់សម្តេចប្រព្រឹត្តទៅរលូននិងចៀសវាងរាល់ឧបសគ្គ។ បន្ទាប់មក ក្រុមយុវជនទាំងអស់បានធ្វើដំណើរទៅកាន់ស្តូប ២ ធ្នូ ដើម្បីបានឃើញជាក់ស្តែង ដែលជាការបញ្ចប់កម្មវិធីទស្សនកិច្ច។ ទោះបីយ៉ាងណា ក្រុមយុវជនទាំងអស់នេះនឹងមានទស្សនកិច្ចជាបន្តដោយឡែក មកកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង, សារមន្ទីរវាលពិឃាតបឹងជើងឯក និងអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

នៅក្នុងដំណើរទស្សនកិច្ចនេះដែរ ក្រុមយុវជនបានសួរសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រប្រទេសកម្ពុជា, ដំណើររបស់សម្តេចតេជោ ហ៊ុន សែន ទៅប្រទេសវៀតណាមដើម្បីរំដោះប្រទេសជាតិ និងអំពីភាពជាអ្នកដឹកនាំរបស់ សម្តេចតេជោ ហ៊ុន សែន ដែលបានដឹកនាំប្រទេសរហូតមកដល់បច្ចុប្បន្ន។

សំណួរសំខាន់ៗ របស់ក្រុមយុវជនខាងលើ គឺស្របជាមួយគោលបំណងដែលមជ្ឈមណ្ឌល ឯកសារកម្ពុជា ចង់ផ្តល់ឱកាសឲ្យយុវជនទាំងអស់សិក្សាឲ្យបានស៊ីជម្រៅ

ទាក់ទងនឹងប្រវត្តិសាស្ត្រ រួមមាន ទី១) ឈ្វេងយល់អំពី «បញ្ហា» ដែលបានកើតមាននៅក្នុងរបបខ្មែរក្រហមបង្កឲ្យប្រជាជនជាងបីលាននាក់ស្លាប់បាត់បង់ជីវិត ហើយប្រទេសជាតិបានធ្លាក់ដល់កម្រិតសូន្យ។ ទី២) ឈ្វេងយល់អំពី«ប្រភពនៃបញ្ហា» ដែល ប៉ុល ពត ចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសជឿនលឿនខាងកសិកម្ម ដោយមិនបានគិតគូរអំពីផលប៉ះពាល់ដល់ជីវិតប្រជាជន ដែលទទួលរងដោយសារការអនុវត្តផែនការរបស់ខ្លួន (ផែនការ៤ឆ្នាំ)។ ទី៣) ឈ្វេងយល់អំពីការ «រំលត់បញ្ហា» ដែលផ្តើមចេញពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ឆ្ពោះទៅប្រទេសវៀតណាម ដើម្បីកៀងគរកម្លាំងរំដោះប្រទេសជាតិ និងការទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកវិញ និង ទី៤) ប្រើប្រាស់វិធីសាស្ត្រផ្ទាល់ខ្លួនដែលបានសិក្សាឈ្វេងយល់ ពីដំណើរទស្សនកិច្ចនេះ ដើម្បី « ដោះ ស្រាយបញ្ហា» និង «ការពារមិនឲ្យបញ្ហាកើតឡើងជាថ្មីម្តងទៀត» ក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។

## ប្រវត្តិមជ្ឈមណ្ឌលឯកសារកោះថ្ម

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង នៃកងយោធពលខេមរ-ភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានផ្ញើលិខិតស្នើសុំបន្ទប់រៀនចំនួន ២បន្ទប់ នៅក្នុងសាលាបឋមសិក្សាប៊ុនរ៉ានី ហ៊ុនសែនកោះថ្ម ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ សម្រាប់រៀបចំជាសារមន្ទីររក្សាទុកឯកសារស្រាវជ្រាវ ដោយសហការរៀបចំ និងប្រតិបត្តិជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ លិខិតពីឯកឧត្តម បណ្ឌិតសភា-ចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពលើសំណើរសុំបន្ទប់សិក្សាចំនួន២នេះ។

ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន ឡុង ដានី, ផេង ពង្សរ៉ាស៊ី, លី កុកឆាយ, ស៊ូ ហ៊្សារីណា, លីម យ៉ុងហួត និងសុខ វណ្ណៈ បានរៀបចំតម្លើងផ្ទាំងពិព័រណ៍រូបថត និងរចនាមជ្ឈមណ្ឌល ឯកសារកោះថ្មនេះឡើង។ ឯកសារពិព័រណ៍បង្ហាញពេលវេលាជាប្រវត្តិសាស្ត្រនេះ យកចេញពី ១) ឯកសារខ្មែរក្រហម ២) ឯកសារអាមេរិក និង៣) ឯកសារវៀតណាម និងរូបភាពទាំងឡាយផ្តើមចេញពីអ្នកថតរូបចំនួន ៥រូប គឺ ១) ម៉ៃ ឡាំ អ្នកថតរូបវៀតណាម, ២) ស៊ីលវ៉ាណា ហ៊្វ័រ អ្នកថតរូបអាមេរិក, ៣) ដេវីត ហ៊ិក អ្នកថតរូបអាមេរិក, ៤) ឆាំង យុ អ្នកថតរូបកម្ពុជា និង៥) ហ៊្គុនណា បឺយស្ត្រម អ្នកថតរូប ស៊ុយអែត និងរូបគំនូរទាំង ៣៦ផ្ទាំង គូរដោយវិចិត្រករ អ៊ុត វឿន។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអ្នករៀបចំពិព័រណ៍នេះ ដើម្បីជាការចាប់ផ្តើមបង្កើតឲ្យមានមជ្ឈមណ្ឌលឯកសារ កោះថ្ម សហការជាមួយក្រុមការងារវិមានឈ្នះឈ្នះ តំបន់ប្រវត្តិសាស្ត្រយោធានៃក្រសួងការពារជាតិ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារប្រវត្តិសាស្ត្រយោធានឹងខិតខំពង្រឹងកិច្ចសហការឲ្យមានការសិក្សាស្វែងយល់ និងស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ឲ្យកាន់តែប្រសើរជាងសព្វថ្ងៃ សម្រាប់ជាចំណេះចេះដឹងដល់យុវជនយុវនារីជំនាន់ក្រោយ។ មជ្ឈមណ្ឌលឯកសារ កោះថ្ម នេះក៏មានតួនាទីជាទីតាំងបណ្តោះអាសន្នសម្រាប់រៀបចំធ្វើសារមន្ទីរ ក្រោមលំហាមេឃមួយ នៅលើផ្ទៃដីនៅចំពីមុខសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម។

រូបថតដែលបានដាក់តាំងបង្ហាញទាំងអស់ គឺជាបណ្តុំរូបថតបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ រូបថតទាំងនេះ បង្ហាញដល់អ្នកទស្សនាអំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលចាប់ផ្តើមពីការធ្វើសង្គ្រាមនៅតាមព្រំប្រទល់កម្ពុជា-វៀតណាម ជាពិសេស នៅតំបន់កោះថ្ម ឃុំទន្លូង និងភូមិមួយចំនួនក្នុងឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ), ការកកើត និងគ្រប់គ្រងប្រទេសទាំងស្រុងរបស់ខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧៥ដល់ ១៩៧៩ ដែលបង្កឲ្យមានមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់ជីវិតប្រជាជនកម្ពុជាជាង ២លាននាក់ និងហេដ្ឋារចនាសម្ព័ន្ធប្រទេសទាំងមូល, ដំណើរឆ្ពោះទៅការផ្តួលរំលំរបបខ្មែរក្រហម និងជីវិតរស់នៅប្រចាំថ្ងៃបន្ទាប់ពីរបបខ្មែរក្រហម ព្រមទាំងភស្តុតាងឧក្រិដ្ឋដែលបន្សល់ទុកពីរបបនេះ រហូតឈានដល់ការផ្តួចផ្តើមគំនិតបង្កើត គោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដើម្បីបង្រួបបង្រួមប្រទេសទាំងមូលដោយសន្តិភាពនិងសន្តិវិធី។

## «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ជ័យ ផុន ៖ គ្រូបង្រៀន

ឪពុករបស់ខ្ញុំបានស្លាប់ដោយជរាពាធមុនពេលដែលរបប លន់ នល់គ្រប់គ្រងប្រទេសកម្ពុជា ដូច្នេះម្តាយខ្ញុំបានប្រកបរបរលក់កន្ទេលដើម្បីទ្រទ្រង់ជីវភាពគ្រួសាររបស់យើង។ ប៉ុន្តែវាមិនគ្រប់គ្រាន់នោះទេ ដូច្នេះហើយបងប្អូនប្រុសរបស់ខ្ញុំពីរនាក់ បានទៅរស់នៅវត្តដោយបួសជាភិក្ខុសង្ឃ។ នៅពេលដែលខ្ញុំមានអាយុ៥ឆ្នាំ ខ្ញុំបានទៅរស់នៅជាមួយពួកគាត់នៅវត្តទៀត។

ខ្ញុំគឺជាសិស្សពូកែម្នាក់ ដែលតែងតែជាប់ចំណាត់ថ្នាក់លេខ១ ឬលេខ២ នៅក្នុងថ្នាក់រៀន។ បន្ទាប់ពីខ្ញុំបញ្ចប់ការសិក្សានៅខេត្តកណ្តាល ខ្ញុំបានមកបន្តការសិក្សារៀនសូត្រនៅសាលាគរុកោសល្យនៅទីក្រុងភ្នំពេញ។ កេង វ៉ាន់សាក់ គឺជានាយក ហើយ សុន សេនដែលក្រោយមកគាត់គឺជារដ្ឋមន្ត្រីក្រសួងការពារជាតិខ្មែរក្រហម គឺជានាយកផ្នែកកម្មវិធីអប់រំនៅសាលា។ សុន សេន គឺជាកូនកាត់ចិន-កម្ពុជា។ គាត់សង្ហារ និងរួសរាយខ្លាំងណាស់។ បន្ទាប់ពីខ្ញុំបានបញ្ចប់ការសិក្សា ខ្ញុំបានធ្វើជានាយកសាលានៅខេត្តកំពង់ចាម។ ដោយសារតែសាលាខ្វះគ្រូបង្រៀន ខ្ញុំបានបង្រៀនសិស្សជាច្រើនថ្នាក់។

នៅឆ្នាំ១៩៦២ ខ្ញុំបានរៀបការជាមួយបងប្អូនស្រីជីដូនមួយរបស់ខ្ញុំឈ្មោះ ប៉ុល យ៉ែម។ ចាប់តាំងពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧២ ខ្ញុំបានបង្រៀននៅសាលាបឋមសិក្សាមួយកន្លែង។ នាយកសាលារបស់ខ្ញុំបានឃោសនាឲ្យខ្មែរក្រហម ប៉ុន្តែខ្ញុំមិនចូលរួមក្នុងការឃោសនានោះទេ។



ជ័យ ផុន (រូបខាងស្តាំ), បងប្រុសឈ្មោះ ជ័យ ផន, ជ័យ ស្បោង និង ជ័យ ផាន់ នៅឆ្នាំ១៩៥៧។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលដែលគ្រាប់បែកចាប់ផ្តើមទម្លាក់ ប្រពន្ធរបស់ខ្ញុំហើយនឹងខ្ញុំបានសម្រេចចិត្តផ្លាស់ទីលំនៅ ដោយយើងបានធ្វើជាសន្តិសុខនៅឯការិយាល័យស្រុកក្បែរទីក្រុងភ្នំពេញ។ នៅពេលដែលស្ថានភាពមិនបានប្រសើរឡើងនៅឆ្នាំ១៩៧៤ យើងបានផ្លាស់ទៅជាយក្រុងភ្នំពេញ ហើយត្រឡប់ទៅបង្រៀនវិញ។

នៅឆ្នាំ១៩៧៥ នៅពេលដែលរបប លន់ នល់ ដួលរលំ យើងត្រូវបានជម្លៀសទៅភូមិកំណើតរបស់ខ្ញុំស្ថិតនៅក្នុងខេត្តកណ្តាល។ គ្រប់គ្នានៅទីនោះដឹងថាខ្ញុំធ្លាប់ធ្វើជាគ្រូបង្រៀន។ នៅពេលដែលប្រធានសហករណ៍សួរខ្ញុំអំពីវិជ្ជាជីវៈរបស់ខ្ញុំ ខ្ញុំបានឆ្លើយដោយស្មោះត្រង់ ប៉ុន្តែមិនបាននិយាយថា ខ្ញុំគឺជាសន្តិសុខនោះទេ។ ប្រសិនបើខ្មែរក្រហមដឹងថា ខ្ញុំប្រើកាំភ្លើង ខ្ញុំនឹងត្រូវសម្លាប់ជាមិនខាន។ ខ្ញុំក៏បានប្រាប់ ថាខ្ញុំចេះសូត្រធម៌ ដូច្នេះខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅធ្វើការនៅក្នុងអង្គភាពនេសាទដែលមានមនុស្សប្រុសបីនាក់។ យើងបានរស់នៅជាមួយប្រជាជនមូលដ្ឋាន ប៉ុន្តែប្រជាជនមូលដ្ឋានមិនពេញចិត្តនឹងខ្ញុំទេ ព្រោះខ្ញុំគឺជាប្រជាជន១៧មេសា។ ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំដឹងពីរបៀបធ្វើការងារជាច្រើនប្រភេទ រួមមាន ស្ទូង នេសាទ ដេរសំណាញ់ ចាក់ថ្នាំ និងចេះកូតទ្រ ដែលជាឧបករណ៍តន្ត្រីប្រពៃណីខ្មែរ។ ដោយសារការខិតខំប្រឹងប្រែងធ្វើការរបស់ខ្ញុំទើបប្រជាជននៅមូលដ្ឋានចាប់ផ្តើមចូលចិត្តខ្ញុំ។

ជារៀងរាល់យប់ប្រធានសហករណ៍បានហៅខ្ញុំទៅកូតទ្រ ជាមួយសមាជិក

ផ្សេងទៀតនៅក្នុងក្រុមតន្ត្រី។ ជាធម្មតា យើងលេងបទ «អតីតយុទ្ធជន និង យុទ្ធនារី កសាងផ្លូវដែក»។ ខ្មែរក្រហមបានចាក់បទចម្រៀងនេះជាប្រចាំតាមឧបករណ៍បំពងសំឡេង ក្នុងអំឡុងពេលហូបអាហាររួមគ្នានៅពេលល្ងាច ដូច្នេះខ្ញុំបានរៀនលេងបទនេះ តាមរយៈទ្រូរបស់ខ្ញុំ។ ជារៀងរាល់ពេលដែលខ្ញុំលេងបទនេះ យោធាបានឲ្យបារីមកខ្ញុំជក់។

ប្រពន្ធរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើស្រែនៅក្នុងសហករណ៍។ ការងាររបស់គាត់គឺពិបាកខ្លាំងណាស់ ហើយគាត់មិនដែលមានអាហារហូបគ្រប់គ្រាន់នោះទេ។ ជួនកាលខ្ញុំយកត្រីដែលខ្ញុំចាប់បាន ហើយផ្ញើរទៅឲ្យគាត់។ ខ្ញុំមិនអាចហូបត្រីទាំងនោះតែម្នាក់ឯងបានទេ ហើយប្រសិនបើអង្គការរកឃើញថា ខ្ញុំលួចលាក់ត្រី ខ្ញុំនឹងត្រូវបានអង្គការសម្លាប់ជាមិនខាន។

នៅថ្ងៃមួយពេលដែលខ្ញុំកំពុងនេសាទស្រាប់តែខ្ញុំបានឮសំឡេងស្រែករួច ហើយក៏ធ្លាក់ចូលទៅក្នុងទឹក។ លុន ដែលជាអ្នកនេសាទជាមួយខ្ញុំបាននិយាយថា មានពេលខ្លះគាត់បានឃើញសាកសពអណ្តែតនៅលើទឹក។ គាត់បានព្យាយាមយកសំណាញ់របស់គាត់ទាញឡើង ប៉ុន្តែវាមានសភាពធ្ងន់ខ្លាំងណាស់ធ្វើឲ្យគាត់មិនអាចលើកឡើងបានឡើយ ហើយបានឃើញសាកសពអណ្តែតជាច្រើនទៀត។ សាកសពត្រូវបានចងដោយខ្សែព្រួរធ្វើពីធាងត្នោត។ សេនាជនបាននាំយកប្រជាជនទៅឆ្ងាយពីភូមិដើម្បីសម្លាប់ជារៀងរាល់យប់។ ខ្ញុំមិនដែលបានសម្រាន្តលក់ស្កប់ស្កល់នោះទេ ព្រោះខ្ញុំមានអារម្មណ៍ភ័យខ្លាច ហើយក៏មិនដឹងថាវេនបន្ទាប់គឺជាវេនរបស់អ្នកណាដែរ។ អង្គការចង់យកខ្ញុំទៅអប់រំ ប៉ុន្តែជាសំណាងល្អប្រជាជនក្នុងភូមិបានអង្វរដល់កម្មាភិបាល កុំឲ្យយកខ្ញុំទៅព្រោះខ្ញុំមិនដែលឈ្លោះជាមួយអ្នកណាទេ។



ជ័យ ផុន ឆ្នាំ១៩៦២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រពន្ធរបស់ ជ័យ ផុន
ឈ្មោះ ប៉ុល យ៉ែម ឆ្នាំ១៩៦០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមចូលមកដល់ប្រទេសកម្ពុជា កម្មាភិបាលខ្មែរក្រហមបានបង្ខំខ្ញុំឲ្យជួយចម្លងពួកគេឆ្លងទន្លេ ដោយប្រើទូកនេសាទរបស់ខ្ញុំ។ កម្មាភិបាលខ្មែរក្រហមទាំងនោះកំពុងរត់គេចខ្លួន។ ខ្ញុំមិនមានភាពក្លាហានគ្រប់គ្រាន់ក្នុងការបដិសេធជាមួយខ្មែរក្រហមនោះទេ ព្រោះខ្មែរក្រហមទាំងនោះប្រដាប់ដោយអាវុធគ្រប់ដៃ។ ទោះបីជាយ៉ាងនេះក្តី ខ្ញុំបានយកពូថៅមកជាមួយ ប៉ុន្តែគ្មាននរណាម្នាក់ក្នុងចំណោមខ្មែរក្រហមទាំងនោះព្យាយាមធ្វើបាបខ្ញុំទេ។

នៅអំឡុងពេលរបបខ្មែរក្រហម ខ្ញុំបានលាក់រូបថតទាំងនេះនៅក្នុងបាវស្រូវ។ កម្មាភិបាលបានឆែកឆេររបស់របររបស់យើងទាំងអស់ ប៉ុន្តែមិនបានរកឃើញនោះទេ។ រូបថតនេះ គឺជាប្រពន្ធរបស់ខ្ញុំដែលបានថតនៅពេលដែលគាត់គឺជាសិស្ស។ គាត់បានរួចផុតពីរបបនេះ ហើយបានស្លាប់ដោយរោគាពាធបន្ទាប់ពីឆ្នាំ១៩៧៩។ គាត់មានអាយុ៥០ឆ្នាំ។ យើងមានកូន៨នាក់ បច្ចុប្បន្ននៅសល់ត្រឹមតែ៥នាក់ប៉ុណ្ណោះ។ កូនស្រីរបស់ខ្ញុំម្នាក់បានស្លាប់ដោយអណ្តាតភ្លើង នៅពេលដែលចង្កៀងប្រេងកាតប្រពន្ធរបស់ខ្ញុំបានកំពប់និងឆាបឆេះ។

បងប្អូនរបស់ខ្ញុំ និងខ្ញុំបានថតរូបនេះសម្រាប់ជាអនុស្សាវរីយ៍។ អ្នកនៅខាងឆ្វេងដៃគឺបង ជ័យ ផន គាត់ធ្លាប់ធ្វើជាទាហានហើយក្រោយមកគាត់បានធ្វើជាបុគ្គលិកពេទ្យនៅឯមន្ទីរពេទ្យមួយនៅទីក្រុងភ្នំពេញ។ គាត់ត្រូវបានជម្លៀសទៅខេត្តបាត់ដំបង គឺជាទីកន្លែងដែលគាត់ និងគ្រួសាររបស់គាត់បានស្លាប់ដោយសារអត់ឃ្លាន។ អ្នកនៅបន្ទាប់គឺ ជ័យ ស្បោង គាត់គឺជាព្រះសង្ឃនៅវត្តសុវតី ដែលបានស្លាប់បន្ទាប់ពីរបបខ្មែរក្រហម។ ជ័យ ដាន់ បានបួសជាព្រះសង្ឃនៅពេលដែលគាត់មានអាយុ១២ ឬ១៣ឆ្នាំ។ គាត់បានបាត់ខ្លួននៅឆ្នាំ១៩៧៥ នៅពេលដែលគាត់ត្រូវបានជម្លៀសទៅខេត្តបាត់ដំបង។ បងប្អូនស្រីរបស់ខ្ញុំឈ្មោះ ជ័យ ស៊ីដាន់ ក៏បានស្លាប់ដែរ។

**ប៊ុន ពីច័ន្ទ និង វេនី ខកហ្គៀល**

*រូបក្របមុខ៖*
*រាជវង្សានុវង្ស និង "បណ្ណាល័យសម្ដេចម៉ែ" នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រារព្ធខួបទី៨នៃការយាង*
*សោយទិវង្គតរបស់សម្ដេចព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ ព្រះវររាជបិតាជាតិខ្មែរ នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២*
*នៅវត្តលង្កា រាជធានីភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ៖*
*រូបក្របក្រោយ ៖ ព្រះឆាយាលក្ខណ៍សម្ដេចព្រះបរមរតនកោដ្ឋ នរោត្ដម សីហនុ ព្រះវររាជបិតាជាតិខ្មែរ*
*នៅព្រះវិហារវត្តលង្កា ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 250, October 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.